ខែ មីនា ឆ្នាំ 2016

196

សូមចូលទៅកាន់គេហទំព័រ www.itcity.com.kh ដើម្បីទាញយកទស្សនាវដ្ដីទីក្រុងពត៌មានវិទ្យាដោយឥតគិតថ្លៃ

ទំនាក់ទំនងផ្សាយពាណិជ្ជកម្ម 010 67 67 67 / 018 9 333337

# IT MAGAZINE ទស្សនាវដ្ដី ទីក្រុង ពត៌មានវិទ្យា

we live with technology

IT CITY MAGAZINE

## មេរោគកុំព្យូទ័រ ដែលគ្រោះថ្នាក់បំផុត

## ស្វែងយល់លក្ខណៈកុំព្យូទ័រ Dell xps 12 2-in-1, Asus X540SA, ZEN AIO PRO, Predater G6



## របៀបប្រើប្រាស់ Google Drive Desktop

## របៀបតាមដានកុំព្យូទ័រ ឬ Tablet ដែលបាត់

## XCOM 2 សង្គ្រាមមនុស្ស វិទ្យាសាស្ត្រ

## វិធីងាយៗក្នុងការ បំលែង PDF ទៅជា Word Document

# Herbal Health

## Jointcare

# ថ្នាំបំប៉ន
# ផ្សំឡើងដោយ
# រុក្ខជាតិធម្មជាតិ ១០០%

មានប្រសិទ្ធិភាពខ្ពស់
ក្នុងការព្យាបាល:

- ✓-រលាកសន្លាក់ឆ្អឹង
- ✓-ជម្ងឺប្រគ្រីវ
- ✓-កាត់បន្ថយការតានតឹង ខ្វល់ខ្វាយក្នុងអារម្មណ៍
- ✓-ការពារជម្ងឺកើតមុន និងរោគរលាកស្បែក
- ✓-រោគសន្លាក់ឆ្អឹងផ្សេងៗ




Herbal Health

ទីស្នាក់ការធំ រាជធានីភ្នំពេញ :
ផ្ទះលេខ 8AE0 ផ្លូវលេខ 156 សង្កាត់វាលវង់
ខណ្ឌ ៧មករា រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ 023 67 68 711 / 088 8651111 / 016 555 889



ដើម្បីសុវត្ថិភាព
លោកអ្នក
- កាមេរ៉ាចាប់យករូបភាពច្បាស់ល្អ
- អាចមើលតាមទូរសព្ទពីចម្ងាយ
- ដំឡើងដោយជាងជំនាញ
មានបទពិសោធន៍ច្រើនឆ្នាំ
- ទទួលដំឡើងគ្រប់ខេត្ត ក្រុង
- តម្លៃថោកសមរម្យ
Computer · Phone · Camera security
សូមអញ្ជើញមកកាន់ Digital Show Room :
ផ្ទះលេខ ៨ AEo ផ្លូវ ១៥៦ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរស័ព្ទ : 023 555 6 777

# ដឹងតែឡូយម៉្ញងជាមួយស្មាតហ្វូន Huawei GR5 បំពាក់មុខងារស្កេនក្រយៅដៃក្នុងតម្លៃទាប !




Huawei គឺជាក្រុមហ៊ុនបច្ចេកវិទ្យាឈានមុខ និងលំដាប់ថ្នាក់លេខ 3 ផ្នែកស្មាតហ្វូនក្នុងពិភពលោកបានចេញលក់ទូរស័ព្ទស្មាតហ្វូនស៊េរីថ្មីបំផុត តម្លៃត្រឹមតែ 259 ដុល្លារ ដែលបំពាក់មុខងារស្កេនក្រយៅដៃ កាន់តែឆ្លាតវៃ ស្រួលប្រើ មានមុខងារច្រើន និងមានលក្ខណៈពិសេសដ៏អស្ចារ្យជាច្រើនទៀត គឺ Huawei GR5។ Huawei GR5 គឺជាស្មាតហ្វូន សំរាប់យុវវ័យមនុស្សជំនាន់ថ្មីប្រើហើយស្រលាញ់និងកាន់តែទាក់ទាញ។

Huawei GR5 បំពាក់នូវមុខងារស្កេនក្រយៅដៃជំនាន់ថ្មីទី 2 ដែលអាចអោយអ្នកប្រើកាន់តែងាយ ស្រួល លឿន កាន់តែឆ្លាតវៃ មានមុខងារច្រើនជាងស្មាតហ្វូនដទៃ។ មិនថាក្រយៅយើង សើម រឺស្ងួត លោកអ្នកអាចប្រើក្រយៅដៃដើម្បីដោះសោរលឿនតែមួយប៉ប្រិចភ្នែក ថតរូបសែលហ្វី អូសក្រយៅដៃមកក្រោមដើម្បីមើល notification ប៉ះក្រយៅដៃដើម្បីបិទសំឡេងនាឡិការោទិ៍ រឺបើក App ដែល ទើបនឹងប្រើថ្មី កាន់តែងាយស្រួលនិងរហ័ស។

បើនិយាយពីតួទូរស័ព្ទវិញ គឺមាំ ហាប់ ធន់ ដែលផលិតពីលោហៈធាតុដោយមានថ្មជាប់និង ម៉ាស៊ីន ដែលធ្វើអោយតួរកាន់តែស្រាល ស្ដើង រលោងស្រស់ស្អាតមើលទៅកាន់តែ ទាក់ទាញ និងពេញចិត្តកាន់តែខ្លាំង។

បើលោកអ្នកមើលវីដេអូ ឬរូបភាព នោះឃើញច្បាស់ដូចធម្មជាតិ ត្រជាក់ភ្នែក ជាមួយនឹងអេក្រង់ ទំហំ 5.5 អ៊ីញ (1080x1920) កំរិត Full High Definition ធ្វើអោយលោកអ្នកពេញចិត្តរាល់គ្រប់ រូបភាព វីដេអូ ក្នុងការប្រើប្រាស់ប្រចាំថ្ងៃ ។

កាមេរ៉ា Huawei GR5 បំពាក់នូវបច្ចេកវិទ្យាថ្មី មានមុខងារ F2.0 Aperture អាចកែរូបមនុស្ស រូបថត ផ្ទៃខាងក្រោយអោយច្បាស់ ឬមិនច្បាស់ជាមួយនឹងសេនស៊ីរប្រភេទ CMOS ថតវីដេអូ ថតយឺតៗ (Slow-motion) ថតវីដេអូលឿន (All Focus) ថតរូបលឿន (Time-lapse) ដែលជួយសំរួលអ្នកថតវីដេអូអាជីព ថតរឿងខ្លីៗ វីវីដេអូ ជាមួយនឹងមុខងារមុខស្អាតរលោងថតម្ហូបអាហារដោយ មានពណ៌គួរអោយចង់ញ៉ាំ និងមើលទៅកាន់តែឆ្ងាញ់ ដែលមានកាមេរ៉ាក្រោយទំហំ 13 PM និងកាមេរ៉ា មុខទំហំ 5MP។

បើនិយាយលក្ខណៈពិសេសដទៃទៀត គឺកាន់តែអោយទុកចិត្ត ដែលមានអង្គប្រតិបត្តិការប្រភេទ Qualcomm Snapdragon 615 (4x1.5Ghz +4x1.2Ghz) ប្រព័ន្ធប្រតិបត្តិការ Android 5.1 + EMUI 3.1 Lite ល្បឿនដំណើរការ RAM 2GB និងទំហំក្នុងម៉ាស៊ីន ROM 16GB ។ ជាងនេះទៅទៀត Hauwei GR5 អាចប្រើបានស៊ីមពីរ និងល្បឿនអ៊ិនធើណិត 4G LTE។ ចំណែកឯថាមពលថ្មខ្លាំង ទំហំ 3000 MAh និងប្រើបានយូរពេញ ១ថ្ងៃ បំពាក់ដោយបច្ចេកវិទ្យាផ្កាច់មុខសន្សំសំចៃថ្មប្រើបានយូរជាងស្មាតហ្វូន។

គួរបញ្ជាក់ផងដែរ Huawei GR5 ដែលទើបនឹងចេញលក់ថ្មីៗនេះ មានលក់នៅគ្រប់ហាងធំៗ នៅទូទាំងប្រទេស ពោលគឺ 25 ខេត្តក្រុង ដែលមានតម្លៃត្រឹមតែ 259 ដុល្លារ ដោយមានថែម កាដូ ដូចជា ស្រោមទូរស័ព្ទខាងក្រោយ និងដងថតរូបសែលហ្វីមួយផងដែរ៕





# DUAL USB CAR CHARGER




## 30% Discount

- Charge all iPhone and iPod models
- Charge all BlackBerry models and other USB powered devices in the car
- Blue LED light indicator



មានលក់នៅហាង **Digital**
**#8AEo** ផ្លូវលេខ១៥៦ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
Tel: 016 555 889, 023 555 6 777 Digital Cambodia www.digital-cambodia.com

# ទស្សនាវដ្តី ទីក្រុងទូរស័ព្ទ

PHONE CITY MAGAZINE



## ចេញផ្សាយរៀងរាល់ថ្ងៃទី ០១ នៃខែនីមួយៗ

### ផ្តល់ជូននូវៈ

- ម៉ូដែលទូរស័ព្ទថ្មីៗ និងរបៀបប្រើប្រាស់ទូរស័ព្ទ
- តារាងតម្លៃទូរស័ព្ទ
- អត្ថបទកម្សាន្ត យ៉ាងសម្បូរបែប
- ងាយស្រួលទាញយក តាមរយៈ Smart Phone ឬ Website

អតិថិជនមិត្តអ្នកអានទាំងអស់អាចទាញយកទស្សនាទីក្រុងទូរស័ព្ទបានដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.phonecity.com.kh ឬសម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការ Android អាចទាញយកកម្មវិធី Phonecity បានតាមរយៈ Playstore ។

# ដើម្បីសុវត្ថិភាពលោកអ្នក



- កាមេរ៉ាចាប់យករូបភាពច្បាស់ល្អ
- អាចមើលតាមទូរសព្ទពីចម្ងាយ
- ដំឡើងដោយជាងជំនាញ មានបទពិសោធន៍ច្រើនឆ្នាំ
- ទទួលដំឡើងគ្រប់ខេត្ត ក្រុង
- តម្លៃថោកសមរម្យ



digital
Computer · Phone · Camera security

**សូមអញ្ជើញមកកាន់** Digital Show Room :
ផ្ទះលេខ ៨ AEo ផ្លូវ ១៥៦ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរស័ព្ទ : 023 555 6 777

# មាតិកា

លេខទី១៩៦ ខែមីនា ឆ្នាំ២០១៦
196 March 2016




ទំព័រ 26

## ព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ

12- ឯកឧត្តម ប្រាក់ សុខុន ចូលរួមពិព័រណ៌គមនា-គមន៍កំរិតពិភពលោកឆ្នាំ 2016 (WMC 2016)...
18- សាមសុងលើកទឹកចិត្តអតិថិជនឱ្យជាវផលិតផលស្របច្បាប់..................................
19- 15 រយលានសារត្រូវបានផ្ញើលើ Telegram ក្នុងមួយថ្ងៃ..................................................
20- កម្មវិធីថ្មីរបស់ Skype Qik អាចផ្ញើវីដេអូខ្លីៗបាន ..................................................

## Accessories Computer

22- G926 Headphone .....................
23- Laser Bacode Reader YHD-3100
24- Mini 2W LED USB Bulb.................
25- Speaker H-301 ..........................

## Computer Review

26- Asus X540..............................
28- Dell XPS 12 2-in-1 ........................
30- Zen Aio Pro PC...............................
32- Acer Predator G6 .........................

## HardWare Review

34- 5D Data Storage Disc អាចផ្ទុកទិន្នន័យបាន 360TB........................
36- Mobile HDD ដែលមានរូបរាងស្តើងបំផុត និងដើរលឿនបំផុត......................................

## ហ្គេមពេញនិយម

42- PLAYDAY 2: WOLF PACK បេសកកម្មឆ្កែចចក.....................................
44- XCOM 2 សង្គ្រាមមនុស្សវិទ្យាសាស្ត្រ .....................

## New Software

46- កម្មវិធីថ្មីៗ ..........................................




ទំព័រ 34-36

AFFORDABLE RELIABLE INTERNET
CITY Link
YOUR OBVIOUS CHOICE
LEADING INTERNET SERVICE PROVIDER

1Mbps get 2Mbps
2Mbps get 4Mbps




023 220 112
www.citylink.com.kh

# មាតិកា

លេខទី១៩៦ ខែមីនា ឆ្នាំ២០១៦
196 March 2016





## ហ្គេមថ្មីៗ

50 - ហ្គេមកុំព្យូទ័រថ្មីៗ

## Quick Study

53- វិធីងាយៗក្នុងការបំលែង File PDF ឱ្យក្លាយ ជា Word Document

## Security

58- មេរោគកុំព្យូទ័រទាំង៥ ដែលមាន ឥទ្ធិពលខ្លាំងក្លា និងគ្រោះថ្នាក់បំផុត..............

## សំណួរមិត្តអ្នកអាន

70 - សំណួរ និងចម្លើយ

## ផលិតផលថ្មីៗ

79- Notebook 9 រូបរាងថ្មីពីក្រុមហ៊ុន Samsung ..................................................

80- ក្រុមហ៊ុន Mouse Computer បង្ហាញកុំព្យូទ័រថ្មី ........................................

81- Arch Dome ធ្វើការយ៉ាងសកម្ម...............

84- កាមេរ៉ាថ្មីរបស់ D-Link ....................

87- ROG G20CB ចំណីអារម្មណ៍ថ្មីសម្រាប់អ្នកលេងហ្គេម...........

## តារាងតម្លៃ

94- តារាងតម្លៃកុំព្យូទ័រ និងគ្រឿងបន្លាស់



**ចាងហ្វាងការផ្សាយ**
អនុបណ្ឌិត : ប៉ុល ច័ន្ទវីរៈ

**នាយកគ្រប់គ្រង**
Mr. : JACKY SAM

**ប្រធានផ្នែកព័ត៌មាន និងនិពន្ធ**
លោក : ឆាន សុផា

**ផ្នែកព័ត៌មាន និងនិពន្ធ**
កញ្ញា : ប៉ោក លក្ខិណា
លោក : ម៉ម សុវណ្ណថា
កញ្ញា : សៀង ចាន់ថូ

**ផ្នែករចនាទំព័រ**
ប្រធាន លោក : ស្វាយ សេរីវុត្ថា

**ផ្នែកទីផ្សារ**
លោក : សាយ ភិរុណ

**ផ្នែកលក់**
លោក : វង់ តុលា

**ផ្នែកគេហទំព័រ**
លោក : ឆាន សុផា
កញ្ញា : ប៉ោក លក្ខិណា



អាសយដ្ឋាន : ផ្ទះលេខ ៨ AEo
ផ្លូវលេខ ១៥៦ សង្កាត់វាលវង់
ខណ្ឌ ៧មករា រាជធានីភ្នំពេញ



**ទំនាក់ទំនងផ្សាយពាណិជ្ជកម្ម**
**010 67 67 67**
**018 9333337**







## បច្ចេកវិទ្យាចុងក្រោយក្នុងការព្រីន

# CONFIDENTIAL CODE



ផ្ញើលេខកូដទៅកាន់អតិថិជនរបស់អ្នកនៅក្នុងវិធីដ៏មានសុវត្ថិភាព **100%** ជាមួយនឹងការច្នៃប្រឌិតថ្មីបំផុតរបស់យើង។




### ប្រសិទ្ធភាព

សាមញ្ញ ងាយស្រួលអនុវត្តន៍ និងងាយស្រួលប្រើប្រាស់

### ភាពអាថ៌កំបាំង

ព័ត៌មានសម្ងាត់អានបានតែម្តងប៉ុណ្ណោះ មិនអាចត្រឡប់ម្តងទៀតបានទេ

### សុវត្ថិភាព

ព័ត៌មានធានាសុវត្ថិភាពទាំងស្រុង ក្នុងអំឡុងពេល និងបន្ទាប់ពីការបោះពុម្ព



ធនាគារអឺរ៉ុប និងក្រុមហ៊ុនធានារ៉ាប់រងជាច្រើនកំពុងប្រើបច្ចេកវិទ្យារបស់យើង:


#8AE0, Sangkat Veal Vong, Khan 7 Makara,
Phnom Penh City, Cambodia
Tel: (855) 16 555 889 / 018 333337

# ឯកឧត្តម ប្រាក់ សុខុន ចូលរួមពិព័រណ៍គមនាគមន៍កំរិតពិភពលោកឆ្នាំ 2016 (WMC 2016) និងទស្សនាស្តង់ក្រុមហ៊ុន HUAWEI





ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៦ នៅទីក្រុងប៉ាសេឡូណាប្រទេសអេស្បាញ បានបើកពិព័រណ៍ទូរសព្ទ័ និងគមនាគមន៍កម្រិតពិភពលោក (MWC 2016) ដែលមានរយៈពេលចាប់ពីថ្ងៃ ២២ ដល់ ២៥ កុម្ភៈ ឆ្នាំ២០១៦។ ក្នុងឱកាសនោះ គណៈប្រតិភូរដែលដឹកនាំដោយ ឯកឧត្តម **ប្រាក់ សុខុន** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក៏បានចូលរួមទស្សនា ប្រជុំ និងផ្លាស់ប្តូរយោបល់ដោយស៊ីជម្រៅជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ ក្រុមហ៊ុន Huawei និងទស្សនាស្តង់ដ៍ធំរបស់ Huawei ផងដែរ ។

នារសៀលថ្ងៃ ២២ កុម្ភៈ នោះដែរ ឯកឧត្តម ក៏បានដឹកនាំគណៈប្រតិភូរទស្សនាស្តង់ដ៍ធំរបស់ Huawei ដែលបានតាំងនិងបង្ហាញក្នុងពិព័រណ៍ទូរសព្ទ័និងគមនាគមន៍កំរិតពិភពលោក (MWC 2016) ដោយយល់ និងស្គាល់អំពីបច្ចេកវិទ្យាទំនើប និងការច្នៃប្រឌិតថ្មីៗ លើវិស័យអ៊ីនធើណិត បណ្តាញតភ្ជាប់ កំរិត 4.5G និង 5G ឧបករណ៍ គមនាគមន៍ ទូរសព្ទ័ Smart phones និងកុំព្យូទ័រកូនកាត់ Huawei Mate Book ជាដើម របស់ក្រុមហ៊ុន ។

នៅក្នុងស្តង់ដ៍ធំ និងប្លុកក្រុមហ៊ុន Huawei ដែលបានដាក់បង្ហាញ ឯកឧត្តម ក៏បានយល់កាន់តែច្បាស់អំពីដំណើរវិវឌ្ឍន៍បច្ចេកវិទ្យា ការច្នៃប្រឌិតថ្មី និងបទពិសោធន៍ជំនាញរបស់ Huawei ក្នុងបណ្តាញ 5G កាលានុវត្តភាពនា ពេលអនាគត មជ្ឈមណ្ឌលសន្ទស្សន៍ និងទីក្រុងសុវត្ថិភាពជាដើមដែលអាចយកបទពិសោធន៍ទាំងនោះ ទៅអនុវត្តក្នុងការអភិវឌ្ឍន៍វិស័យ ICT (បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍) ក្នុងពេលអនាគតនៅកម្ពុជា។

ឯកឧត្តម **ប្រាក់ សុខុន** បានផ្លាស់ប្តូរយោបល់ពិភាក្សាស៊ីជម្រៅជាមួយលោក Pang Jimin នាយកផ្នែកទំនាក់ទំនងជាមួយរដ្ឋាភិបាលនៅទូទាំងពិភពលោកនៃក្រុមហ៊ុន Huawei និងលោក Lyu Qingchen (CEO) នាយកប្រតិបត្តិការជាន់ខ្ពស់ក្រុមហ៊ុន Huawei ប្រចាំនៅប្រទេសកម្ពុជាផងដែរ។ ឯកឧត្តម **ប្រាក់ សុខុន** មានប្រសាសន៍ និងកោតសរសើរថា " ក្រុមហ៊ុន Huawei និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានសហប្រតិបត្តិការទូលាយក្នុងវិស័យបណ្តុះបណ្តាលធនធានមនុស្ស វិទ្យាស្ថាន បណ្តាញអ៊ីនធើណិត និង Cloud Computing ជាដើម ។ Huawei សម្រេចបាននូវសមិទ្ធិផលដ៏ល្អប្រសើរនៅកម្ពុជានិងនៅទូទាំងពិភពលោក ។ ឯកឧត្តម សង្ឃឹមថា Huawei នឹងអភិវឌ្ឍន៍កាន់តែល្អ ហើយក៏រំពឹងថាក្រសួងនឹងធ្វើកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យក៏ដូចជាបច្ចេកវិទ្យាថ្មីៗ ជាមួយ Huawei អោយកាន់តែស៊ីជម្រៅ ដើម្បីរួមវិភាគទានធំធេងក្នុងការ អភិវឌ្ឍន៍វិស័យ ICT នៅកម្ពុជា៕"




EMAXX™ 4G
Internet - WIMAX - Fiber Optics - Telecom Services
4G SPEED
AT YOUR
FINGERTIPS
No. 99, Preah Norodom,
Level 1, Phnom Penh
info@emaxxtelecom.com
www.emaxxtelecom.com
023 999 818
YOUR INTERNET
SERVICE PROVIDER

MEKONGNET
CONNECTING YOU ALL




Speed Up
YOUR BUSINESS
MOVE TO US

023 22 66 22
www.mekongnet.com.kh sales@corp.mekongnet.com.kh





# ក្រុមហ៊ុន Nissan បង្ហាញកៅអីបញ្ជាស្វ័យប្រវត្តិក្នុងការិយាល័យរបស់ខ្លួន

តើឧបករណ៍អ្វីខ្លះទៅដែលអាចបញ្ជាដោយស្វ័យប្រវត្តិបាន? ពិតជាគួរឱ្យភ្ញាក់ផ្អើលយ៉ាងខ្លាំងជាមួយកៅអីបញ្ជាស្វ័យប្រវត្តិ។ ការពិតត្រឹមតែកៅអីបញ្ជាស្វ័យប្រវត្តិ វាមិនមែនជារឿងអស្ចារ្យខ្លាំងដូចការផលិតឡានបញ្ជាស្វ័យប្រវត្តិមែន ប៉ុន្តែយ៉ាងហោចណាស់កៅអីទាំងនេះមិនមិនទាមទារប្រាក់រាប់ម៉ឺនដុល្លារសម្រាប់ទិញវាដូចឡាននោះទេ។

ក្រុមហ៊ុន Nissan បានបង្ហាញវីដេអូខ្លីបមួយស្តីពីការគ្រប់គ្រងកៅអីក្នុងបន្ទប់ធ្វើការ។ កៅអីទាំងនោះអាចផ្លាស់ទីបានដោយខ្លួនឯងដោយគ្រាន់តែទះដៃម្តងប៉ុណ្ណោះ ឧទាហរណ៍ក្នុងការិយាល័យដែលមានកៅអីមួយចំនួនដែលពុំមានសណ្តាប់ធ្នាប់ ប៉ុន្តែក្រោយពីទះដៃតែម្តង កៅអីទាំងអស់បានប្តូរទីតាំងដោយខ្លួនឯងចូលជួរ និងត្រង់កន្លែងយ៉ាងមានសណ្តាប់ធ្នាប់បំផុត។

កាន់តែអស្ចារ្យនៅពេលដែលយើងអង្គុយលើកៅអីនោះ ហើយស្ថិតនៅខុសទីតាំង ពេលនោះយើងគ្រាន់តែទះដៃម្តងប៉ុណ្ណោះ កៅអីចាប់ផ្តើមធ្វើការដូរចង្កូតដូចឡានដែលអាចបង្វិលពីក្រោយមកមុខ ហើយចូលចតទីតាំងដើមដូចឡានថយចូលចំណតដែរ៕








# DUAL USB CAR CHARGER




# 30%
## Discount



- Charge all iPhone and iPod models
- Charge all BlackBerry models and other USB powered devices in the car
- Blue LED light indicator

មានលក់នៅហាង Digital
#8AEo ផ្លូវលេខ១៥៦ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
Tel: 016 555 889, 023 555 6 777 Digital Cambodia www.digital-cambodia.com


Blogger
LINE
1.5 SPEED MB
UPLOAD 3MB
25$
GET ONE MONTH FREE
Wicam
The best connection
#113, St. 271, Sangkat Boeung Salang, Khan Toul Kok, Phnom Penh.
Telephone: (855) 23 22 40 40 / (855) 23 22 25 35
Fax: (855) 023 22 25 26
E-mail:info@wicam.com.kh / sales@wicam.com.kh
facebook.com/wicamcorporate
twitter.com/wicamisp

# សាមសុងលើកទឹកចិត្តអតិថិជនឲ្យជាវផលិតផលស្របច្បាប់

ក្រុមហ៊ុនសាមសុងបានចាប់ផ្តើមប្រើ sticker "Cambodia Privilege" នៅគ្រប់ផលិតអេឡិចត្រូនិចសាមសុង (Samsung Consumer Electronics) ដូចជា ម៉ាស៊ីនត្រជាក់ ទូរទស្សន៍ ទូទឹកកក ម៉ាស៊ីនបោកសម្លៀកបំពាក់ និងផលិតផលអេឡិចត្រូនិចដទៃទៀត ដែលមាននៅក្នុងទីផ្សារកម្ពុជានៅសប្តាហ៍នេះ ដើម្បីធានាថាគ្រប់អតិថិជនដែលជាវផលិតផលេអេឡិចត្រូនិចរបស់សាមសុង ទទួលបាននូវផលិតផលពិតរបស់ក្រុមហ៊ុន និងជៀសវាងការខាតបង់ប្រយោជន៍ផ្សេងៗ។

អតិថិជនទាំងអស់ដែលជាវសម្ភារៈអេឡិចត្រូនិចប្រើប្រាស់ក្នុងគេហដ្ឋានរបស់សាមសុងអាចសួររកផលិតផលដែលមានបិទសញ្ញា "Cambodia Privilege" បណ្ណធានាជាភាសាខ្មែរសញ្ញា "1 YEAR Official Warranty" និងសញ្ញាតែមប្រិយ៍ពន្ធគយ។ ក្នុងករណីដែលផលិតផលអេឡិចត្រូនិចប្រើប្រាស់ក្នុងគេហដ្ឋានរបស់សាមសុង ពុំមានបិទគ្រប់សញ្ញាទាំងបីខាងលើ ឬមានតែសញ្ញាណាមួយក្នុងចំណោមសញ្ញាទាំងបីខាងលើនោះបញ្ជាក់ថាផលិតផលនោះជាផលិតផលមិនស្របច្បាប់ ឬជាផលិតផលក្លែងក្លាយ។




អត្ថប្រយោជន៍នានាដែលអតិថិជននឹងទទួលបានពីការជាវផលិតផលអេឡិចត្រូនិចសាមសុងសម្រាប់ ប្រើក្នុងគេហដ្ឋានដែលនាំចូលស្របច្បាប់រួមមានដូចជា៖

១-ទទួលបាននូវការធានាពេញមួយឆ្នាំពីក្រុមហ៊ុនសាមសុងលើការជួសជុល និងថែរក្សាពីមជ្ឈមណ្ឌលសេវាកម្មរបស់សាមសុងដែលមានអ្នកជំនាញជាច្រើននាក់។

២-ទទួលបានផលិតផលគុណភាពខ្ពស់ដែលត្រូវបានផលិតឡើងតាមប្រព័ន្ធភ្លើងនិងកត្តាអាកាសធាតុនៃប្រទេសកម្ពុជានិងគុណភាពជាលក្ខណៈអន្តរជាតិ។

៣-ទទួលបានអត្ថប្រយោជន៍ពេលមានកម្មវិធីផ្តល់ជូនផ្សេងៗពីក្រុមហ៊ុនសាមសុង។




រាល់ការជាវផលិតផលអេឡិចត្រូនិចសាមសុងដែលស្របច្បាប់មានន័យលោកអ្នកកំពុងតែជួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការទប់ស្កាត់នូវផលិតផលដែលនាំចូលគេចពន្ធនានា ដើម្បីធានាបាននូវតម្លាភាពនៃការប្រកួតប្រជែងស្របច្បាប់ និងទទួលបានចំណូលពីការបង់ពន្ធសម្រាប់ថវិកាជាតិ ក៏ដូចជាគាំទ្រនូវផលិតផលដែលនាំចូលស្របច្បាប់ដើម្បីចូលរួមបំពេញកាតព្វកិច្ចជាពលរដ្ឋល្អ និងដើម្បីការរីកចំរើនដល់ប្រទេសកម្ពុជាទាំងអស់គ្នា។

ដើម្បីស្វែងរកព័ត៌មានបន្ថែមនិងទទួលបានព័ត៌មានថ្មីៗ អត្ថបទ និងឯកសារផ្សេងៗ សូមមើលគេហទំព័រ news.samsung.com៕

# 15 លានសារ ត្រូវបានផ្ញើលើ Telegram ក្នុងមួយថ្ងៃ

បន្ទាប់ពីបង្ហាញខ្លួនបានពីរឆ្នាំ បណ្តាញទំនាក់ទំនងដ៏មានប្រជាប្រិយភាព Telegram បានប្រកាសពីកំណើនចំនួនអ្នកតម្លើង និងអ្នកប្រើប្រាស់របស់ខ្លួន។

មកទល់ពេលនេះអ្នកប្រើប្រាស់សេវាកម្ម Telegram មានចំនួន 100 លាននាក់ក្នុងមួយខែ ដែលជាចំនួនគួរឱ្យស្ញប់ស្ញែងបំផុត។ ក្រុមហ៊ុនបានបង្ហាញពីតួលេខអ្នកប្រើប្រាស់ថ្មីមានចំនួន 350,000 នាក់ ដែលជាកំណើនមួយដ៏ខ្លាំងនៃការប្រើប្រាស់សេវាកម្មរបស់ខ្លួន។ កាន់តែអស្ចារ្យទៀតនោះ មានសារចំនួន 15 លានសារដែលត្រូវបានផ្ញើឱ្យគ្នាទៅវិញទៅមក។

ទោះបីជាយ៉ាងណា Telegram គឺជាកម្មវិធីប្រកួតប្រជែងមួយជាសេវាកម្មផ្ញើសារលើទូរស័ព្ទផ្សេងទៀត ជាពិសេសលើ WhatsApp របស់ក្រុមហ៊ុន Facebook។ ទោះជាយ៉ាងនេះក៏សេវាកម្មនេះមិនទាន់មានសក្តានុពលខ្លាំងដូច WhatsApp នៅឡើយ ព្រោះរបាយការណ៍ថ្មីៗនេះបញ្ជាក់ថា មានអ្នកប្រើ WhatsApp កើនដល់ចំនួន 1 រយលាននាក់។

សម្រាប់អ្នកប្រើ Telegram នៅតែបន្តកើនឡើងជាលំដាប់ទោះមិនទាន់ដល់ចំនួនកំពូលក៏ដោយ៕



# កម្មវិធីថ្មីរបស់ Skype Qik អាចផ្ញើវីដេអូខ្លីៗបាន

ក្រុមហ៊ុន Microsoft បានកាន់កាប់ Skype ជាបណ្តាញរបស់ខ្លួន ជាពិសេសក្រុមហ៊ុនទើបតែបង្ហាញសេវាកម្មថ្មីមួយទៀត Qik ជាសេវាកម្មផ្ញើសារជាវីដេអូ។ សេវាកម្មនេះនឹងដាក់ឱ្យប្រើប្រាស់ជាសារធារណៈក្នុងខែមីនានេះ។




ក្រៅពីអាចជជែកគ្នាជាក្រុមបានយ៉ាងសប្បាយរីករាយ Skype Qik app អាចឱ្យអ្នកថតជាវីដេអូផ្ញើដែលមានរយៈ 42 វិនាទី និងអាចចែកចាយទៅបុគ្គល ឬក្នុងក្រុមបានបន្ថែមទៀត។ ក្រុមហ៊ុន Skype បានលើកឡើងថា ដើម្បីឈានដល់ការបង្ហាញកម្មវិធីនេះ ក្រុមហ៊ុនបានសិក្សាពី filter ជាច្រើនប្រភេទដើម្បីឱ្យប្រាកដថាមានអ្នកធ្វើរឿងនេះលើ Skype។ ជាលទ្ធផលមុខងារដែលបានបន្ថែមជារបាសម្រាប់ការផ្ញើសារជាវីដេអូត្រូវបានសម្រេច ហើយគំនិតរបស់ក្រុមហ៊ុនគឺដាក់វាលើ Qik៕



# 5G ជិតមកដល់ហើយ តើអ្នកត្រៀមខ្លួនហើយឬនៅ?

ក្រុមហ៊ុន Verizon ទើបតែបានបង្ហាញសមិទ្ធិផលថ្មីរបស់ខ្លួនលើវេទិកា MWC ក្នុងក្រុង Barcelona។ ចំណែកឯក្រុមហ៊ុន Big Red បានធ្វើការយ៉ាងសកម្មជាមួយក្រុមហ៊ុនធំៗ ល្បីៗផ្សេងទៀត ក្នុងការសាកល្បងបច្ចេក-វិទ្យាល្បឿនអ៊ិនធើណេតថ្មី 5G ដែលអាចផ្តល់ជូនដល់អតិថិជនបាន។

ក្រុមហ៊ុន Verizon បានបន្តធ្វើការយ៉ាងដុតដៃដុតជើងជាមួយក្រុមហ៊ុនល្បីៗទូទាំងសាកលលោកដូចជាក្រុមហ៊ុន Apple, Intel, Samsung, Nokia, Qualcomm និង Ericsson ដើម្បីអភិវឌ្ឍន៍បំណែកតូចនៃល្បឿនអ៊ីនធើណេត 5G ឱ្យក្លាយជាកាពិតប្រើការបានឆាប់បំផុត។ ម៉្យាងទៀតក្រុមហ៊ុន Verizon បានហៅការជួបជុំនោះថា "5G Technology Forum"។ ក្រុមហ៊ុន Verizon បានដាក់គម្រោង សាកល្បងល្បឿនអ៊ីនធើណេតលើកទៅប៉ុន្មានខែក្រោយទៀត និងបានធ្វើការងារជាមួយក្រុមហ៊ុន wireless ធំៗជាច្រើនៗនៅអាស៊ីដើម្បីឈានទៅដល់ការចែកចាយល្បឿនអ៊ីនធើណេត 5G បានក្នុងឆ្នាំ 2017។

5G ល្បឿនអ៊ិនធើណេតថ្មីដែលអាចប្រើប្រាស់ភ្ជាប់បាននៅគ្រប់ទីកន្លែងក្នុងផ្ទះ ការិយាល័យ ប្រើប្រាស់លើទូរទស្សន៍ 4K កាន់តែមានលក្ខណៈលេចធ្លោ។ ក្រុមហ៊ុន Verizon មានបទពិសោធន៍កាន់តែច្រើនក្នុងការធ្វើការងារនេះ ហើយថ្មីៗនេះក្រុមហ៊ុនទើបតែបានបញ្ចប់គម្រោងមួយជាមួយ Fios Cable Internet ហើយឈានមកដល់ការអភិវឌ្ឍន៍ 5G ដោយខ្លួនឯង។

ទាក់ទងនឹងល្បឿនអ៊ីនធើណេតថ្មីនេះ ក្រុមហ៊ុន Samsung បានចេញគម្រោងថានឹងបង្ហាញឧបករណ៍ដែលប្រើបណ្តាញ 5G នៅឆ្នាំ 2020 ប៉ុន្តែនៅពេលដែលក្រុមហ៊ុន Verizon ធ្វើការកាន់តែលឿននោះក្រុមហ៊ុន Samsung កាន់តែផលិតឧបករណ៍នោះដោយប្រើ 3G លឿនជាងមុនបីឆ្នាំ៕



# ឧបករណ៍អេឡិចត្រូនិចជំនួយ Accessories




## G926 នាំអ្នកទៅកាន់ពិភពនៃសង្គ្រាម

នេះគឺជាបទពិសោធន៍ថ្មីសម្រាប់ការកម្សាន្តផ្សេងៗនៅក្នុងកុំព្យូទ័ររបស់អ្នកជាក់ស្តែងដូចជាការលេងហ្គេមតែម្តង។ ដោយឧបករណ៍នេះជាកាសស្តាប់ត្រចៀកមួយប្រភេទដែលអាចដំណើរការទៅបានគឺអាស្រ័យទៅនឹងខ្សែ USB ដោតភ្ជាប់ទៅកាន់កុំព្យូទ័រ។ វាត្រូវបានរចនាឡើងស្របតាមស្តង់ដារនៃការផលិតឧបករណ៍នៅក្នុងជំនាន់ទី 2 ដែលមានទម្ងន់ស្រាលក្រាស់ ហើយផលិតចេញពីសារធាតុដែលមានគុណភាពខ្ពស់ជាច្រើនប្រភេទបញ្ចូលគ្នាផងដែរ។ ចំពោះនៅទីតាំងបំពងសំឡេងរបស់វាវិញគឺថាមានបំពាក់ទៅដោយអេប៉ុងដែលមានសភាពទន់ ហើយអាចគ្របផ្ទៃនៃត្រចៀករបស់អ្នកបានជិតល្អ ហេតុនេះហើយទើបធ្វើឱ្យអ្នកទទួលអារម្មណ៍ថាអ្នកកំពុងអង្គុយនៅក្នុងស្ថានភាពពិតជាក់ស្តែងអញ្ចឹងដែរ។ ជាមួយនឹងកង់បង្វិលដែលមាននៅលើឧបករណ៍នេះ ហើយនឹងការរចនាហ៊ុំព័ទ្ធទៅដោយប្រព័ន្ធភ្លើងលម្អដ៏ស្រស់ស្អាតនោះ អ្នកអាចកំណត់កម្រិតនៃសំឡេងតាមចិត្តរបស់អ្នកបាន៕




## YHD-3100
## រហ័ស ឆ្លាតវៃ និងងាយស្រួលប្រើ

នេះគឺជាឧបរណ៍ជំនួយដល់ការប្រើប្រាស់នៅក្នុងហាងទំនិញ ឬបណ្តារផ្សារទំនើបនានា ដើម្បីឱ្យការលក់ផលិតផលអាចដំណើរការបានរហ័សទាន់ចិត្ត។ អ្នកមិនចាំបាច់ត្រូវការខ្សែ adapter អ្វីនោះទេដោយឧបករណ៍នេះអាចដំណើរការទៅបានដោយប្រព័ន្ធ bluetooth 2.0 / 3.0 / 4.0 ហើយអាចប្រើប្រាស់ជាមួយនឹងប្រព័ន្ធប្រតិបត្តិការមួយចំនួនដូចជាប្រព័ន្ធប្រតិបត្តិការ Windows ប្រព័ន្ធប្រតិបត្តិការ Android និងប្រព័ន្ធប្រតិបត្តិការ iOS ក៏បានដែរ។ វាពិតជាផ្តល់ភាពងាយស្រួលក្នុងការប្រើប្រាស់ខ្លាំងណាស់ ដោយលោកអ្នកអាចប្រើប្រាស់វាជាមួយឧបករណ៍ប្រើប្រាស់ផ្សេងៗទៀតរបស់អ្នករួមមាន កុំព្យូទ័រលើតុ កុំព្យូទ័រយួរដៃ Tablets ឬស្មាតហ្វូនក៏គ្មានបញ្ហាដែរ។ សម្រាប់ដំណើរការរបស់វាវិញ ឧបករណ៍មួយប្រភេទនេះដំណើរការបានរហ័ស និងឆ្លាតវៃ ពីព្រោះថាវាបានបំពាក់ទៅដោយបច្ចេកវិទ្យាពិសេសៗដូចជា ARM និង DSP ជាដើម៕




# បំពេញការងារដោយគ្មានការរំខានដល់អ្នកដទៃពី
## Mini 2W LED USB Bulb

តើអ្នកតែងតែបំពេញការងាររបស់អ្នកបន្ថែមនៅពេលយប់មែនទេ? បើដូច នេះមែនតើអ្នកគួរធ្វើបែបណា ដើម្បីចៀសវាងនូវការរំខានចំពោះមិត្តភក្តិ ឬក្រុមគ្រួសាររបស់អ្នក? កុំបារម្ភ អំពូលភ្លើងខ្នាតតូច ដែលដើរដោយខ្សែ USB មួយនេះអាចជួយអ្នកបាន។ វាជាឧបករណ៍ដែលមានភាពងាយស្រួលក្នុងការប្រើប្រាស់បំផុត ដោយអ្នកគ្រាន់តែដោតភ្ជាប់វាទៅកាន់កុំព្យូទ័រ ឬឧបករណ៍ផ្សេងទៀតរបស់អ្នកនោះអ្នកនឹងទទួលបានពន្លឺគ្រប់គ្រាន់សម្រាប់បំពេញការងាររបស់អ្នក ជាពិសេសនោះអ្នកអាចបិទ ឬបើកដោយគ្រាន់តែចុចកុងតាក់ដែលមាននៅលើខ្សែស្រាប់ប៉ុណ្ណោះ។ ម្យ៉ាងទៀតលោកអ្នកអាចដាក់ឧបករណ៍នេះនៅតាមខ្លួនគ្រប់ពេលបាន ពីព្រោះវាមានទម្ងន់ស្រាល ហើយងាយស្រួលទុកដាក់។ អ្វីដែលសំខាន់នោះគឺ វាបានបំពាក់ទៅដោយអំពូលដែលបញ្ចេញពន្លឺបានច្បាស់ ហើយមិនប៉ះពាល់ដល់ភ្នែករបស់អ្នកនោះទេ ទោះបីជាអ្នកប្រើប្រាស់វារយៈពេលយូរក៏ដោយ៕

# បង្កើនបរិយាកាសរីករាយនៅក្នុងផ្ទះ ជាមួយ H-301

ឧបករណ៍ H-301 ជាជម្រើសល្អបំផុតសម្រាប់កុំព្យូទ័រ និងឧបករណ៍ប្រើប្រាស់ជាច្រើនទៀតនៅក្នុងគេហដ្ឋានរបស់អ្នក ដូចជា ទូរទស្សន៍ ថេប្លេត ស្មាតហ្វូន និង mp3 player ជាដើម សម្រាប់បង្កើនបរិយាកាសកម្សាន្តរីករាយដល់អ្នក និងអ្នកនៅជុំវិញអ្នកផងដែរ។ វាជាឧបករណ៍បំពងសំឡេងដែលប្រើប្រាស់បច្ចេកវិទ្យាប្លែកពីគេ ខ្លាំងជាងគេ ហើយមានរូបរាងតូចល្អម។ ដោយសារតែឧបករណ៍ H-301 នេះបានបំពាក់ទៅដោយប្រព័ន្ធ bass ដែលមានទំហំ 5.25 inches នៅក្នុងប្រអប់ឈើបិទជិតនោះ ដូចនេះទើបអ្នកអាចទទួលបានសំឡេងច្បាស់ ធ្ងន់ និងពិរោះ គ្មានសំឡេងរំខានអ្វីបន្តិចនោះឡើយ។ ហើយទន្ទឹមនឹងនេះ ឧបករណ៍ដ៏ទំនើបមួយនេះត្រូវបានប្រើប្រាស់ជាមួយនឹងខ្សែ USB សម្រាប់តភ្ជាប់ទៅកាន់បណ្ដាឧបករណ៍របស់អ្នក៕





# កាន់តែរំភើបជាមួយការប្រើប្រាស់ ASUS X540 រាងស្តើង



គួរឱ្យចាប់អារម្មណ៍យ៉ាងខ្លាំងជាមួយកុំព្យូទ័រយួរដៃថ្មីរបស់ក្រុមហ៊ុន ASUS មានរហ័សនាមថា ASUS X540 ដែលជាប្រភេទកុំព្យូទ័រយួរដៃផ្តល់ភាពទាក់ទាញ និងស្រស់ស្អាតបែបទាន់សម័យ។ ASUS X540 Series រចនាឡើងដោយប្រើឈីប Intel® ដែលមានសក្តានុពលខ្លាំងក្នុងការគ្រប់គ្រងគុណភាពបង្ហាញនានាលើអេក្រង់កុំព្យូទ័រ ក៏ដូចជាដំណើរការ Key។ NVIDIA® GeForce® 900 ជាក្រាហ្វិកដែលមានមុខងារសម្បូរបែបក្នុងការបន្ថែមគុណភាពក្រាហ្វិករូបភាពឱ្យកាន់តែច្បាស់ និងសក្តិសមសម្រាប់អ្នកចូលចិត្តលេងហ្គេមកម្សាន្តផ្សេងៗ ឬចាក់វីដេអូមើល។ សម្រាប់អ្នកធ្វើការ ឬអ្នកលេងហ្គេមផ្ទុកទិន្នន័យរបស់ខ្លួនបានយ៉ាងមានសុវត្ថិភាពជាមួយថាសផ្ទុកទិន្នន័យទំហំ 12GB បូកផ្សំបច្ចេកវិទ្យា Windows 10 ដែលជំរុញ platform ឱ្យមានលក្ខណៈប្រសើរ។

## ធ្វើការបញ្ជូនទិន្នន័យបានកាន់តែលឿន និងរហ័សជាមួយ Easier Connections និង USB Type-C

USB Type-C មិនត្រឹមតែត្រូវបានគេប្រើលើការបញ្ជូនទិន្នន័យនោះទេ ប៉ុន្តែគេថែមទាំង





យកវាមកប្រើប្រាស់លើកុំព្យូទ័រនេះដែលផ្តល់ភាពងាយស្រួលក្នុងការភ្ជាប់ ជាពិសេសវាបន្ថែមល្បឿនបញ្ជូន និងចែកចាយទិន្នន័យរហូតដល់ទៅ 3.1 Gen 1 ទំហំ 5Gbit/s។ ល្បឿននេះអាចឱ្យអ្នកបញ្ជូនរឿងទំហំ 2GB ពី Cloud មកកុំព្យូទ័រប្រើពេលតិចបំផុតតិចជាងពីរវិនាទី។ ទោះជាផត USB Type-C បានផ្តល់ល្បឿនលឿនក្នុងការបញ្ជូនទិន្នន័យក៏កុំព្យូទ័រនេះមានភ្ជាប់ផតផ្សេងៗជាច្រើនទៀតរួមមាន៖ USB 3.0, USB 2.0, HDMI, VGA output ផត SD/SDHC/SDXC, RJ-45 Ethernet និងផតចាក់ឌីសបានច្រើនប្រភេទ DVD Super Multi។

ការរចនាប្រើ hardware, software, tuning និង SonicMaster បញ្ចូលគ្នាបង្កើតបានប្រព័ន្ធសំឡេងដ៏ល្អបំផុតជា notebook PC audio។ ការសរសេរកូដបានល្អធ្វើឱ្យប្រព័ន្ធសំឡេងរបស់វាលឺច្បាស់ជាមួយនឹងអំព្លី គ្រាប់បាសធំៗដែលបំពងសំឡេងបានធំ និងលឺបានឆ្ងាយ។ អ្នកកាន់តែសប្បាយរីករាយជាមួយការចាក់បទចម្រៀង កម្សាន្ត ចាក់រឿងមើល លេងហ្គេម ដោយផ្តល់សំឡេងលឺច្បាស់។

ម្យ៉ាងទៀត គ្រាន់តែក្រលេកឃើញភ្លាម អ្នកប្រាកដជាចូលចិត្តចង់បានកុំព្យូទ័រប្រភេទនេះមកប្រើប្រាស់ដោយសារវាមានទម្ងន់ 1.9kg ងាយស្រួលយកតាមខ្លួនចេញក្រៅផ្ទះមិនធ្ងន់ពេក។ សម្រាប់គម្របរបស់វាវិញមានលក្ខណៈភ្លឺរលើបរលោងស្រោបដោយលោហៈធាតុដែលផ្តល់សោភ័ណភាពដ៏ស្រស់ស្អាតបន្ថែមទៀតលើកុំព្យូទ័រនេះ។



សម្រាប់កម្រិតបង្ហាញលើអេក្រង់កុំព្យូទ័រនេះបានប្រើបច្ចេកវិទ្យាពណ៌ដែលប្រើសីតុណ្ហភាពសមស្របដ៏សម្បូរបែបដែលមើលលើអេក្រង់ភ្លឺច្បាស់ មិនប៉ះពាល់ភ្នែក និងវាបានបង្ហាញភាពស្រស់ស្អាតយ៉ាងត្រជាក់ភ្នែកអាចទាក់ចិត្តអ្នកគ្រប់គ្នា។ សម្រាប់ពន្លឺ LED panels បានកាត់បន្ថយពន្លឺខៀវដែលធ្វើឱ្យប៉ះពាល់ដល់ភ្នែកជាមួយនឹងមុខងារ ASUS Eye Care មានដំណើរការយ៉ាងប្រសិទ្ធភាពក្នុងការបញ្ចុះពន្លឺខៀវរហូតដល់ទៅ 33% ដែលធ្វើឱ្យភ្នែករបស់អ្នកត្រជាក់មិនក្រហាយក្រោយពីប្រើប្រាស់៕







# Dell XPS 12 2-in-1

## បំពាក់បច្ចេកវិទ្យាដ៏អស្ចារ្យ



ក្រុមហ៊ុន Dell បញ្ចេញកុំព្យូទ័រជំនាន់ថ្មីរបស់ខ្លួនដែលត្រូវបានគេទទួលស្គាល់ថា Dell XPS 12។ Dell XPS 12 ត្រូវវាបានរចនាឡើងដោយមានរូបរាងស្រស់ស្អាត និងសមត្ថភាពខ្លាំងអាចបំពេញមុខងារបានប្រសើរបំផុត ។

Dell XPS 12 ជាកុំព្យូទ័រយួរដៃទាន់សម័យមានរូបរាងស្រស់ស្អាត។ កុំព្យូទ័រនេះត្រូវបានផ្គុំឡើងពីបន្ទះពីរផ្សេងគ្នា មួយជាអេក្រង់ដែលមានទំហំ 12 អ៊ីង និងផ្ទាំងមួយទៀតជា Keyboard។ អេក្រង់តូចមួយនេះផ្តល់កម្រិតពន្លឺសមស្រប និងមានប្រព័ន្ធកាត់បន្ថយពន្លឺខៀវមិនប៉ះពាល់ដល់ភ្នែក។ សម្រាប់ Keyboard វិញ មានគ្រាប់ Key ជាច្រើនស្ថិតក្នុងចន្លោះសមស្របសម្រាប់រៀបម្រាមដៃ ជាពិសេសគ្រាប់នីមួយៗរបស់វាមានលក្ខណៈទន់ មិនគាំង ឬងាយរបូតទេ។ លើគ្រាប់ Key នីមួយៗមានទំហំ 1.9mm ផ្តល់ភាពងាយស្រួលដល់ការផ្លាស់ប្តូរម្រាមដៃរបស់អ្នកបានកាន់តែងាយរហ័ស និងងាយស្រួលចុចសមស្របនឹងទីតាំងរបស់ម្រាមដៃ។ សម្រាប់ touchpad សម្រាប់



ប៉ះបញ្ជាកំណត់លើអេក្រង់វិញជាប្រភេទកញ្ចក់ថ្លា មានទំហំតូចល្មម ហើយថែមទាំងមានលក្ខណៈរអិលងាយស្រួលរំកិលម្រាមដៃ។

កុំព្យូទ័រនេះប្រើឧបករណ៍បំពងសំឡេងដែលផ្តល់នូវគុណភាពសំឡេងខ្ពស់ មានលក្ខណៈលឺធំ ហើយជាពិសេសអ្នកអាចចាក់ចម្រៀង ចាក់វីដេអូទស្សនាដោយទទួលបានសំឡេងច្បាស់ល្អបំផុត។ នៅផ្នែកភ្ជាប់រវាងអេក្រង់ និង Keyboard របស់វាពុំមានប្រើត្រចៀកនោះទេ ប៉ុន្តែវាត្រូវបានជំនួសត្រចៀកភ្ជាប់ត្រង់ស៊ុមដែលអាចបង្វិលអេក្រង់បាន បញ្ឈរ ឬផ្ងារដោយអេក្រង់នោះជាប់នឹងស៊ុមដដែល។ សម្រាប់ប៊ូតុង Power វិញត្រូវបានរចនាមកមានរាងមូលស្ថិតនៅផ្នែកខាងលើជ្រុងខាងឆ្វេងវិញ។

កាន់តែពិសេសអ្នកអាចដោះវាមកប្រើជាថេប្លេតដែលមានរូបរាងស្រស់ស្អាតមុខងារសម្បូរបែបមិនចាញ់ថេប្លេតផ្សេងៗទៀតលើទីផ្សារឡើយ។ ថេប្លេតនេះបំពាក់អេក្រង់ជាប្រភេទកញ្ចក់ថ្លា Corning Gorilla Glass៕



## លក្ខណៈទូទៅ

Screen : 12.5" 4K Ultra HD (3840 x 2160) touch
CPU : 6th Generation Intel® Core™ M5 Processor (4M Cache, up to 2.7 GHz)
OS : Windows 10 Home
RAM : 8GB LPDDR3-1600MHz
HDD : 256GB Solid State Drive
Graphic : Intel® HD Graphics 515
Port : USB 3.1 Gen 2 (10Gbps)
Native DisplayPort 1.2
VGA
HDMI
Ethernet and USB-A via Dell Adapter (Sold Separately)
Dimension : Height: 16-25mm | Width: 291mm | Depth198mm | Weight: 1.27kg




# កាន់តែមានភាពស៊ីវីល័យជាមួយ Zen AiO Pro PC

កុំព្យូទ័រដ៏ទំនើបហើយទាន់សម័យ Zen AiO Pro ជាសមិទ្ធផលថ្មីពីក្រុមហ៊ុន Asus ដែលរចនាមកមានរូបរាងទាក់ទាញ និងមុខងារប្រសើរជាងកុំព្យូទ័មួយចំនួនផ្សេងទៀតលើទីផ្សារ។ បច្ចេកវិទ្យាថ្មីនឹងផ្តល់ភាពធន់ ការពារពីការកោសឆូតដោយធាតុអាឡុយមីញ៉ូម ផ្តល់ភាពស្រស់ស្អាតតាំងពីចុងម្ខាងដល់ចុងម្ខាង។

PC ដ៏គួរឱ្យទាក់ទាញមួយនេះបំពាក់អេក្រង់ប្រភេទ 4K/UHD (3840 x 2160) បូកផ្សំនឹងបច្ចេកវិទ្យាអេក្រង់ស្រស់ស្អាតតាំងពីចុងម្ខាងដល់ចុងម្ខាង ទំនើប ជាមួយនឹងការផ្តល់សមត្ថភាពប៉ះបញ្ជាបានទាំងម្រាមដប់របស់អ្នក ជាពិសេសវាបានផ្តល់នូវរូបភាពដ៏ស្រស់ស្អាត និងបើកបង្ហាញដល់ជ្រុងគែមកម្រិត 178°។ អ្នកទទួលបានពន្លឺគ្រប់គ្រាន់ និងរូបភាពច្បាស់ជានិច្ចមិនថាអ្នកមើលពីជ្រុងខាងណាមកនោះទេ។

អេក្រង់របស់ Zen AiO Pro មានបណ្តុំពណ៌ច្រើនប្រភេទ NTSC ចំនួន 82% Adobe RGB 85% និង sRGB100% ដែលនេះជាបច្ចេកវិទ្យាថ្មរបស់ Zen AiO Pro ផ្តល់ពណ៌កាន់តែស្រស់ស្អាត និងទាក់ទាញ ជាពិសេសធ្វើឱ្យពណ៌របស់រូបថតស្រស់ស្អាតដូចធម្មជាតិ។

**ថាមពលខ្លាំងក្លា**

Zen AiO Pro ផ្តល់នូវដំណើរការរលូនមាន





ថាមពលខ្លាំងក្លា ដោយវាត្រូវបានគេភ្ជាប់ឈីប Intel® Core™ i7 ដ៏ពេញនិយម អមដោយក្រាហ្វិកប្រភេទ NVIDIA® GeForce® GTX™ 960M ផ្តល់នូវក្រាហ្វិករូបភាពកាន់តែប្រសើរសមល្មម និងមានល្បឿនលឿនសម្រាប់អ្នកចូលចិត្តលេងហ្គេមកម្សាន្តនានាកាន់តែមានលក្ខណៈ



សម្បូរបែប។ សម្រាប់សមត្ថភាពភ្ជាប់ខាងក្នុងម៉ូដែលនេះភ្ជាប់មេម៉ូរីប្រភេទ DDR4 រួមជាមួយដូច M.2 PCIe® Gen3 x4 SSD មានល្បឿនលឿនបច្ចេកវិទ្យាចុងក្រោយ។

ថាមពលរបស់វាកាន់តែខ្លាំង និងមានដំណើរការកាន់តែប្រសើរដោយមានឥទ្ធិពលដ៏ពិសេសរបស់ Windows 10 Home ដែលជាប្រព័ន្ធដំណើរការដ៏ទាន់សម័យផ្តល់ថាមពលដល់កម្មវិធីកាន់តែប្រសើរ។ Zen AiO Pro ជាម៉ូនីទ័រដែលមានសមត្ថភាពច្រើន វាអាចឱ្យអ្នកផ្ញើទិន្នន័យទុកលើ cloud ដែលមានល្បឿនលឿនសម្រាប់ផ្ទាល់ខ្លួន ជាពិសេសវាផ្តល់សុវត្ថិភាព និងលក្ខណៈបុគ្គលសម្រាប់ប្រើប្រាស់ឯកសាររបស់អ្នក។ នេះបញ្ជាក់ថា ទោះជាអ្នករក្សាឯកសាររបស់អ្នកតាមរបៀបណាក៏ដោយ មិនថាលើទូរស័ព្ទ លើកុំព្យូទ័រអ្នកអាចបើកវាបានគ្រប់ទីកន្លែង និងលើឧបករណ៍គ្រប់ប្រភេទ ហើយអ្នកថែមទាំងទទួលបានទំហំផ្ទុកទិន្នន័យ Web Storage របស់ ASUS ដែលមានទំហំ 100 GB ដោយឥតគិតថ្លៃពេញមួយឆ្នាំ។

សម្ថភាពបន្ថែមទៀតសម្រាប់ការផ្ញើ និងចែកចាយឯកសារមានដូចជា៖ HomeCloud, PC Link និង SyncUp។

Asus Zen AiO Pro Z240IC ផ្តល់នូវសមត្ថភាពដ៏ល្អប្រសើរបំផុត ជាពិសេសអេក្រង់បង្ហាញមានគុណភាព 4K ផ្តល់ទំហំផ្ទុកទិន្នន័យធំថែមទាំងមានល្បឿនលឿនជាងទំហំផ្ទុកទិន្នន័យរបស់ iMac របស់ក្រុមហ៊ុន Apple ទៀតផង៕

# លេងហ្គេមកាន់តែសប្បាយជាមួយ Acer Predator G6




Acer Predator G6 ជាកុំព្យូទ័រហ្គេមជំនាន់ថ្មីរបស់ក្រុមហ៊ុន Acer ដែលមានសក្តានុពលសម្រាប់អ្នកលេងហ្គេមគ្រប់គ្នាជាពិសេសការរចនារូបរាងមានភាពទាក់ទាញ និងកាន់ស្រស់ស្អាតដែលបន្ថែមសោភ័ណភាពរបស់វាកាន់តែពិសេស។ វាជាកុំព្យូទ័រហ្គេមដែលខ្លាំងក្នុងចំណោមកុំព្យូទ័រហ្គេមល្បីៗផ្សេងទៀត ជាពិសេសរបស់វាមានលក្ខណៈកាន់តែប្រសើរជាងកុំព្យូទ័រហ្គេមជំនាន់មុនៗ NVidia GeForce GTX 980។

## ការរចនា

កុំព្យូទ័រនេះត្រូវបានរចនាឡើងចំឡែកខុសពីកុំព្យូទ័រធម្មតាដោយមានរង្វះកាត់ទទឹកជាប្រអប់តូចៗចំនួនប្រាំបីថ្នាក់។ នៅចន្លោះថ្នាក់កណ្តាលៗមានភ្ជាប់ផត និងរន្ធផ្សេងៗជាច្រើនទៀត។ នៅលើប្រអប់កាត់ទទឹងថ្នាក់ទីពីរ មានផ្លាក Predator រំលេចដោយពណ៌ស្រស់ឆើតយ៉ាងស្រស់ស្អាត។





វាជាកុំព្យូទ័រហ្គេមដែលមិនមានប្រើ backlight។ ធុងនេះត្រូវបានរចនាឡើងដោយមានភាពទាក់ភ្នែកបំផុត គ្រាន់តែក្រឡេកឃើញអ្នកនឹងចាប់អារម្មណ៍ពីការរចនា និងរូបរាងរបស់វាដែលប្រើពណ៌ខ្មៅរលើបរលោងតែម្តង។ ធុងកុំព្យូទ័រនេះមានទំហំមិនធំខាងនោះទេ វាមានទំហំទាំងបីត្រឹមតែ21.8x18.2x8.3អ៊ីង ងាយស្រួលទុកដាក់បានគ្រប់ទីកន្លែង។

## គុណភាពបង្ហាញគឺខ្លាំង

Predator G6 មានថាមពលគ្រប់គ្រាន់សម្រាប់កំណត់ setting របស់ហ្គេមឱ្យរឹងមាំ ជាពិសេសក្រាហ្វិករបស់វា Nvidia GeForce GTX 980 ផ្តល់នូវកម្រិតរូបភាពច្បាស់ត្រជាក់ភ្នែក កុំព្យូទ័រទាំងមូលមានល្បឿនលឿនគ្រប់ដំណើរការ។ កាន់តែពិសេសកាតក្រាហ្វិករបស់វាមានមេម៉ូរីទំហំ 4GB សម្រាប់ផ្ទុក ហ្គេកបានយ៉ាងច្រើនប្រភេទ។ សម្រាប់អ្នកចូលចិត្តលេងហ្គេម Star Wars Battle front បានផ្តល់ហ្វ្រេមចំនួន 60 frame ក្នុងមួយវិនាទី ថែមទាំងមានល្បឿនលឿន។ ធុងនេះភ្ជាប់ផតយ៉ាងសម្បូរបែបក្នុងនោះរួមមានរន្ធដោតកាស Ethernet line-in, line-out, microphone jacks និងផត USB 2.0 ចំនួនពីរ រួមជាមួយផត USB 3.0 inputs ចំនួនបី។ ក្រៅពីនេះវាមានផតសម្រាប់ភ្ជាប់ទីកាន់ឧបករណ៍បង្ហាញ Display Ports ផ្សេងៗទៀតចំនួនបី។

## សមត្ថភាពភ្ជាប់សម្បូរបែប

Predator មិនត្រឹមតែផ្តល់ភាពសប្បាយរីករាយដល់អ្នកក្នុងការលេងហ្គេមនោះទេ ប៉ុន្តែថែមទាំងជា PC ដែលភ្ជាប់សមត្ថភាពកាន់តែប្រសើរ។ ម៉ាស៊ីនរបស់វាភ្ជាប់ប្រព័ន្ធដំណើរការ Intel Core i7-6700K និងភ្ជាប់អង្គចងចាំទំហំ 16GB ដែលមានល្បឿនលឿន និងអាចទាញយកហ្គេមបានម្តងពីរក្នុងពេលតែមួយមានល្បឿនលឿន រួមទាំងអាចដំណើរការស្តែនប្រព័ន្ធម៉ាស៊ីនទាំងអស់បានកាន់តែប្រសើរបំផុត។ SSD ទំហំ 256GB របស់ Predator មានល្បឿនគួរឱ្យចង់បាន ដែលនេះជាល្បឿនលឿនជាង SSD របស់ Bolt 3 ដែលជាមធ្យមមានល្បឿនប្រហែល 218 MBps៕



# 5D Data Storage Disc អាចផ្ទុកទិន្នន័យបាន 360TB និងរក្សាទុកបានរហូតដល់ 14 ពាន់លានឆ្នាំ




ថ្មីៗនេះ ក្រុមអ្នកស្រាវជ្រាវបានធ្វើការអភិវឌ្ឍនូវ Optical Data Storage ថ្មីដែលអាចធ្វើការផ្ទុកទិន្នន័យចូលបានទំហំដល់ទៅ 360TB នៅលើ Quartz Disk របស់វា។ របកគំហើញថ្មីនេះមានប្រយោជន៍យ៉ាងសំខាន់សម្រាប់ដោះស្រាយទៅលើបញ្ហាក្នុងការរក្សាទុកទិន្នន័យបានធំ។ អ្នកស្រាវជ្រាវដែលមកពីសាកលវិទ្យាល័យ Southampton University របស់ចក្រភពអង់គ្លេសបានធ្វើការបង្កើតនូវបច្ចេកវិទ្យា Digital Data Storage នេះដោយប្រើប្រាស់នូវពន្លឺឡាស៊ែរដើម្បីផ្ទុកទិន្នន័យបានច្រើនដល់ទៅ 360TB នឹងអាចរក្សាទុកបានរយៈពេល 14 ពាន់លានឆ្នាំថែមទៀត។

ការប្រើប្រាស់នូវបន្ទះកញ្ចក់នេះ អ្នកវិទ្យាសាស្ត្រមកពីសាកលវិទ្យាល័យ Optoelectronics Research Centre (ORC) បានធ្វើការអភិវឌ្ឍការបញ្ជូនឯកសារទិន្នន័យ និងផ្ទុកទិន្នន័យនៅលើបច្ចេកវិទ្យាឡាស៊ែរនេះដែលមានឈ្មោះថា 5D Digital Data។




អ្នកស្រាវជ្រាវប្រើប្រាស់នូវកម្លាំងឡាស៊ែរដើម្បីធ្វើការបញ្ចូលទិន្នន័យចូលទៅក្នុង Quartz Disk នៅត្រង់ឈីបតូចរបស់វានោះ។ វាមានបីស្រទាប់ ហើយនឹងមានមីក្រូឈីបតូចៗនៅពីលើផ្នែកនីមួយៗទៀត។ ការផ្លាស់ប្តូរបច្ចេកវិទ្យាក្នុងការផ្ទុកទិន្នន័យបានច្រើននេះរឹតតែធ្វើឱ្យការបញ្ជូនទិន្នន័យបានលឿន ហើយរក្សាទុកបានយូររាប់លានឆ្នាំ។

ក្រោយពីទទួលបានជោគជ័យក្នុងការតេស្តសាកល្បងប្រើប្រាស់នូវ 5D Optical Disc នេះ រឿងបន្តរដែលអ្នកស្រាវជ្រាវត្រូវធ្វើគឺសាកល្បងបញ្ចូលទិន្នន័យ King James Bible ចូលទៅកាន់ឈីបតូចមួយនេះ។ ក្រុមការងារបានធ្វើការបញ្ចូលនូវការងារធំៗជាច្រើនទៅកាន់កញ្ចក់ឈីបមួយនេះដែលមានទាំងពីឯកសារធំៗរបស់ Universal Declaration of Human Rights, Newton´s Opticks និង Magna Carta ជាដើម។

បន្ទាប់ពីទិន្នន័យបានធ្វើការបញ្ចូលកាន់តែច្រើនទៅៗ ពួកគេអាចធ្វើការវាស់ស្ទង់ដឹងថាបន្ទះ Quartz ឈីបមួយនេះអាចធ្វើការផ្ទុកទិន្នន័យបានទំហំដល់ទៅ 360TB។ ពួកគេបញ្ជាក់បន្ថែមថា ទិន្នន័យដែលរក្សាទុកនៅលើបន្ទះឈីបនេះគឺនៅប្រើប្រាស់បានធម្មតាហើយអាចរក្សាទុកបានរយៈពេលយូរជាង 13.8 ពាន់លានឆ្នាំ បើទោះបីជាសីតុណ្ហភាពប្រែប្រួលកើនឡើងដល់ 350 ដឺក្រេហ្វារិនហៃក៏ដោយ។

ក្រុមអ្នកស្រាវជ្រាវបានខិតខំប្រឹងប្រែងរហូតបានសម្រេចនូវការផលិតនូវឈីបតូចដែលបានផ្ទុកទិន្នន័យបានធំបំផុតដែលអាចនឹងប្រើប្រាស់នៅពេលខាងមុខឆាប់ៗនេះ។ អ្នកវិទ្យាសាស្ត្រជាច្រើននាក់ទៀតក៏កំពុងតែធ្វើការបង្កើតនូវបន្ទះឈីបដូចគ្នានេះដែរតែនៅមិនទាន់បានទទួលជោគជ័យដោយសាកលវិទ្យាល័យ Southampton University នោះទេ។

របកគំហើញថ្មីនេះអាចជាការផ្លាស់ប្តូរដ៏ធំសម្រាប់ពិភពលោកព្រោះមនុស្សគ្រប់គ្នាសុទ្ធតែមានទិន្នន័យច្រើនហើយមិនដែលចេះគ្រប់គ្រាន់នោះទេ។ ប្រហែលជាក្រុមអ្នកសាវ្រជ្រាវមួយនេះអាចនឹងទទួលបានពានរង្វាន់ Nobel ផងដែរដោយសារតែរបកគំហើញនេះនៅឆ្នាំនេះ។









# Mobile HDD ដែលមាន រូបរាងស្ដើងបំផុត និងដើរលឿនបំផុត




សម្រាប់លោកអ្នកដែលកំពុងតែស្វែងរកនូវ Storage Hard Drive ដែលមានរូបរាងស្ដើង និងដំណើរការលឿនបំផុតនោះ ពេលនេះក្រុមហ៊ុន SEAGATE បានធ្វើការប្រកាសបង្ហាញនូវ Hard Drive ស៊េរីថ្មីដែលមានឈ្មោះថា "Mobile HDD" ដែលមានទំហំ 2TB ល្បឿនលឿនបំផុត និងស្ដើងបំផុតនៅក្នុងលោក។ តាមរយៈការបញ្ជាក់ពីក្រុមហ៊ុន SEAGATE បានឱ្យដឹងថា Hard Drive នេះប្រើប្រាស់នូវ SATA 3 Interface

ដែលមានន័យថាលោកអ្នកអាចប្រើប្រាស់បានជាមួយនឹង Laptop ឬកុំព្យូទ័រលើតុរបស់អ្នកបានងាយស្រួលបំផុត។

ក្រុមហ៊ុន SEAGATE បានប្រកាសថា "ការរក្សាទុកទិន្នន័យ 1TB នៅលើ Hard Drive នៅមិនទាន់គ្រប់គ្រាន់សម្រាប់អ្នកប្រើប្រាស់នោះទេ ទើបក្រុមហ៊ុន SEAGATE សម្រេចចិត្តធ្វើការបង្កើតនូវ Seagate Mobile HDD ដែលមានសមត្ថភាពផ្ទុកទំហំដល់ទៅ2TBល្បឿនលឿនបំផុតនៅក្នុងលោក និងមានប្រវែងត្រឹមតែ 7 មីលីម៉ែត្រតែប៉ុណ្ណោះ។" បើប្រៀបធៀបជាមួយនឹងកុំព្យូទ័រនៅពេលបច្ចុប្បន្ន ស្តង់ដារដែលគេនិយមប្រើប្រាស់គឺ SATA 6GB/s ព្រោះវាងាយស្រួលក្នុងការប្រើប្រាស់ហើយថែមទាំងអាចធ្វើការប្រើប្រាស់បានជាមួយនឹង Laptop បានច្រើន។ ជាមួយនឹងទំហំធំដល់ទៅ 2TB បានធ្វើ ឱ្យ Mobile HDD មិនត្រឹមតែផ្ទុកទិន្នន័យបានទំហំធំដូចជារូបភាពបានច្រើនដល់ទៅ 200,000 សន្លឹក បទចម្រៀងបាន 250,000 បទ និងវីដេអូដែលមានកម្រិតភាពច្បាស់ខ្ពស់បាន 124 ម៉ោង។ Mobile HDD មានពីរទំហំសម្រាប់ធ្វើការជ្រើសរើសគឺ 1TB និង 2TB ។

ក្រុមហ៊ុន SEAGATE ក៏បញ្ជាក់ផងដែរថា Mobile HDD ថ្មីនេះមានទំងន់ស្រាលជាងមុន 25% ហើយវាអាចប្រើប្រាស់បានជាមួយនឹងកុំព្យូទ័រលើតុ និងនៅលើ Notebook ជាដើម។ Mobile HDD នឹងក្លាយជាផលិតផលដែលទទួលការចាប់អារម្មណ៍ខ្លាំងដោយសារតែលក្ខណៈពិសេសរបស់វា ព្រោះវាមិនត្រឹមតែអាចផ្ទុកទិន្នន័យបានទំហំដល់ទៅ 2TB ប៉ុណ្ណោះទេប៉ុន្តែវាថែមទាំងអាចធ្វើការរក្សាទិន្នន័យបានច្រើនប្រភេទផ្សេងៗគ្នាល្បឿនលឿនបំផុតទៅតាមចំណង់ចំណូលចិត្តរបស់អ្នកប្រើប្រាស់៕











# រីករាយជាមួយ Office 2016 ថ្មីសម្រាប់កំព្យូទ័រ Mac



កាន់តែពិសេសជាមួយកម្មវិធី Office 2016 ដែលអាចឱ្យលោកអ្នកធ្វើការងារដោយងាយស្រួល ព្រោះវាអាចដំណើរការលើ កុំព្យូទ័រ PC កុំព្យូទ័រ Mac ថេប្លេត ព្រមទាំងស្មាតហ្វូនផ្សេងៗទៀតផងដែរ។

**Office ដែលបានរចនាឡើងសម្រាប់ Mac**

ចាប់ផ្តើមយ៉ាងលឿនជាមួយ ជំនាន់ថ្មីនៃកម្មវិធី Word, Excel, PowerPoint, Outlook និង OneNote ដោយបានធ្វើការរួមបញ្ចូលគ្នានៃក្រុមគ្រួសាររបស់កម្មវិធី Office និងមុខងាររបស់ unique Mac។

### Word




លោកអ្នកអាចធ្វើការបង្កើតកែច្នៃ និងចែករំលែកនូវភាពស្រស់ស្អាតជាមួយអ្នកជំនាញលើឯកសារ។

ការបង្កើតផ្នែកនៃការច្នៃប្រឌិត និងឧបករណ៍ពិនិត្យឡើងវិញនៅក្នុង Word ធ្វើឱ្យងាយស្រួលក្នុងការបង្កើតការកែច្នៃឯកសារ។ ការបង្ហាញពីភាពយល់ដឹងថ្មីមួយដែលពាក់ព័ន្ធព័ត៌មានអត្ថបទជាមួយបណ្ដាញខាងក្នុង Word។ ផ្ទាំងរចនាអនុញ្ញាតឱ្យអ្នកគ្រប់គ្រងប្លង់រូបរាង ពណ៌ និងពុម្ពអក្សរក្នុងឯកសារទាំងមូល។ ទទួលបានកាន់តែច្រើនក្នុងការធ្វើកាងាររួមគ្នាដោយប្រើឧបករណ៍ដែលមានស្រាប់នៅក្នុងដើម្បីចែករំលែកនិងការពិនិត្យឯកសារឡើងវិញ។ មានមនុស្សជាច្រើនអាចធ្វើការលើឯកសារដែលដូចគ្នាក្នុងពេលតែមួយនិងប្រើមតិយោបល់ធ្វើការសន្ទនាខាងស្ដាំជាប់នឹងអត្ថបទពាក់ព័ន្ធ។

### Excel




វិភាគ និងមើលឃើញតួលេខនៅក្នុងវិធីថ្មីនិងវិធីសាស្ត្រដែលងាយស្រួលយល់។ នេះជាកម្មវិធី Excel ថ្មីសម្រាប់ Mac អាចធ្វើឱ្យអ្នកងាយស្រួលក្នុងការស្វែងយល់។ ការប្រើក្ដារចុចបែបកាត់ដែលធ្លាប់ស្គាល់និងភាពប្រសើរឡើងក្នុងការបញ្ចូលទិន្នន័យដូចជាកំណត់រូបមន្តនិងការបំពេញដោយស្វ័យប្រវត្តិភ្លាមៗធ្វើឱ្យអ្នកមានផលិតភាពបន្ថែមទៀត។ កម្មវិធី Excel ជួយអ្នកនឹកគិតទិន្នន័យរបស់អ្នកដោយបានផ្ដល់អនុសាសន៍គំនូសតាងដែលល្អបំផុតសម្រាប់តួលេខរបស់អ្នក និងអនុញ្ញាតឱ្យអ្នកមើលជម្រើសផ្សេងគ្នាយ៉ាងឆាប់រហ័ស។ PivotTable slicer ថ្មីជួយឱ្យរកឃើញលំនាំនៅក្នុងទិន្នន័យមួយភាគធំ។

### PowerPoint




បង្កើតបទបង្ហាញ និងបង្ហាញគំនិតរបស់អ្នកជាមួយនឹងទំនុកចិត្ត។ ចូលទៅកាន់បទបង្ហាញបន្ទាប់របស់អ្នកដែលពោរពេញទៅដោយភាពជឿជាក់។ មើលការបង្ហាញជាថ្មីនៅក្នុង PowerPoint ដែលបង្ហាញស្លាយ( Slide )កំពុងស្ថិតនៅស្លាយបន្ទាប់ កំណត់ចំណាំដោយប្រើសំឡេង និងពេលវេលានៅលើកុំព្យូទ័រ Mac ខណៈពេលដែលធ្វើបទបង្ហាញតែប៉ុណ្ណោះដើម្បីឱ្យអ្នកទស្សនិកជននៅលើអេក្រង់ដែលធំ។ Animation pane ថ្មីអាចជួយក្នុងការរចនា និងចលនានៃការកែសម្រួល ហើយដំណើរការផ្លាស់ប្ដូរស្លាយបានល្អ។ មានភាពងាយស្រួលក្នុងការចែករំលែកបទបង្ហាញរបស់អ្នក ហើយអញ្ជើញអ្នកផ្សេងទៀតទៅធ្វើបទបង្ហាញដូចគ្នាក្នុងពេលដំណាលគ្នា។

### OneNote

ទាញយកគំនិតរបស់អ្នកនៅក្នុងសៀវភៅឌីជីថលផ្ទាល់ខ្លួនរបស់អ្នក។ ការចាប់យក ការរៀបចំ និងការចែករំលែកគំនិតជាមួយសៀវភៅកត់ត្រាឌីជីថលដែលអាចដំណើរការលើឧបករណ៍ផ្សេងៗទៀត។ ស្វែងរករបស់ដែលត្រូវការបានយ៉ាងលឿនជាមួយម៉ាស៊ីនស្វែងរកលឿនបំផុតដែលតាមដានស្លាកសញ្ញារបស់អ្នក សន្ទស្សន៍កំណត់ចំណាំដែលបានសរសេរ និងការរៀបចំអក្សរនៅក្នុងរូបភាពជាមួយអក្សរសរសេរដោយដៃ។ កែទម្រង់ការកត់ត្រារបស់អ្នកទៅតាមអ្វីដែលចង់បានដូចជា អក្សរដិត អក្សរផ្តេក អក្សរមានបន្ទាត់ពីក្រោម អក្សរចំណាំ បន្ថែមឯកសារ រូបភាព និងតារាង។

ផ្តល់ភាពងាយស្រួលចែករំលែកសៀវភៅកត់ត្រាជាមួយមិត្តភក្តិ គ្រួសារ ឬមិត្តរួមការងារដូច្នេះអ្នកគ្រប់គ្នាអាចធ្វើការរួមគ្នានៅលើគម្រោងការធ្វើដំណើរ ភារកិច្ចក្នុងគ្រួសារ ឬគម្រោងការងារ។





### Outlook

រក្សាអ្វីដែលបានរៀបចំជាមួយអ៊ីម៉ែល និងប្រតិទិនដែលលឿន ហើយមើលឃើញស្អាត។ ការគ្រប់គ្រងអ៊ីម៉ែល ប្រតិទិន ទំនាក់ទំនង និងការងារដែលមានភាពលំបាក ដូចនេះកម្មវិធី Outlook ថ្មីសម្រាប់ Mac ជំរុញឱ្យមានការគាំទ្រសំបុត្រដូច្នេះប្រអប់សំបុត្ររបស់អ្នកនឹងធ្វើការ update ជានិច្ច។ ទិដ្ឋភាពការសន្ទនាមានភាពប្រសើរឡើងដោយស្វ័យប្រវត្តិ ប្រអប់សំបុត្ររបស់អ្នករៀបចំជាខ្សែស្រឡាយសន្ទនា ដូច្នេះអ្នកនឹងមិនចាំបាច់តាមរកសារដែលទាក់ទងម្តងទៀត។ ហើយការមើលសារថ្មីពីមុនផ្តល់ឱ្យអ្នកនូវប្រយោគដំបូងនៃអ៊ីម៉ែលខាងក្រោមបន្ទាត់ប្រធានបទមួយ ដូច្នេះអ្នកអាចសម្រេចចិត្តយ៉ាងលឿនបើអ្នកចង់អានវាឥឡូវនេះឬវិលត្រឡប់មកវិញនៅពេលក្រោយ។

### ធ្វើការបានគ្រប់ពេលវេលាគ្រប់ទីកន្លែង

បង្កើតឯកសារដែលមានភាពអស្ចារ្យ ហើយទទួលបានការយល់ឃើញថ្មី និងការបង្ហាញដោយទំនុកចិត្ត នៅគ្រប់ទីកន្លែងគ្រប់ពេលវេលា។ ជាមួយកម្មវិធី Office ដែលល្អសម្រាប់ ថេប្លេត ទូរស័ព្ទស្មាតហ្វូន និង web លោកអ្នកនឹងទទួលបានអ្វីដែលអ្នកត្រូវការ។ លោកអ្នកអាចធ្វើការពិនិត្យឡើងវិញ កែប្រែ វិភាគ និងការបង្ហាញជាមួយភាពមិនប្រែប្រួលហើយស្រដៀងនឹង User interface ដែលងាយស្រួលប្រើប្រាស់សម្រាប់ប្រើនៅលើឧបករណ៍ចល័តរបស់អ្នក។ លោកអ្នកអាចធ្វើការកែប្រែដោយសេរីនៅលើឧបករណ៍ជាមួយអេក្រង់ដែលមានទំហំតូចជាង 10.1 អ៊ីង។



## កម្មវិធី Office ដែលប្រសើរជាងគេជាមួយ Office 365

ជាមួយកម្មវិធីរបស់ Office លោកអ្នកអាចរក្សាទំនាក់ទំនងដោយភ្ជាប់ទៅកាន់អ្វីដែលសំខាន់ដូចជា មិត្តភក្តិ ក្រុមគ្រួសារ គម្រោង និងឯកសារ។ ដំណើរការកម្មវិធី Office ដែលអ្នកប្រើនិងឯកសារដែលលោកអ្នកត្រូវការតភ្ជាប់ចេញពីកុំព្យូទ័រលើតុទៅកាន់ឧបករណ៍ចល័ត។



## Office នៅលើ PC និង Mac

ធ្វើការតម្លើង Office នៅលើកុំព្យូទ័ររបស់អ្នកជាមួយ Office 365 វានឹងធ្វើការ updates ដោយស្វ័យប្រវត្តិ។



## អត្ថប្រយោជន៍មុខងារលើទូរស័ព្ទចល័ត

ទទួលបានផលប្រយោជន៍ពីការដោះសោរដូចជា ការកែប្រែ ទំរង់ និងសមាសិពន្ធកម្រិតខ្ពស់នៅលើឧបករណ៍របស់អ្នក។



## ទទួលយកភាពទាំងអស់គ្នា

លោកអ្នកនឹងទទួលបានការរក្សាទុកទិន្នន័យ 1 TB នៅលើ OneDrive ដើម្បីរក្សាបាននូវទំនាក់ទំនងសំខាន់របស់ឯកសារ នៅគ្រប់ទីកន្លែង នៅគ្រប់ឧបករណ៍។

## ការបង្កើតសម្រាប់ការងារជាក្រុម

ធ្វើបានកាន់តែច្រើនដោយការរួមគ្នាប្រើឧបករណ៍ built-in ដើម្បីធ្វើការចែករំលែក ការពិនិត្យនិងការកែសម្រួលឯកសារ ការធ្វើបទបង្ហាញ និងកំណត់សម្គាល់៕







# បេសកកម្មឆ្កែចចក PLAYDAY 2: WOLF PACK

រឿងរ៉ាវដែលកើតឡើងនៅក្នុងរដ្ឋ Sunshine State ដែលគ្រប់គ្រងដោយលោក Mitchell ដែលជាអ្នកមានលុយ និងមានអំណាចនៅក្នុងរដ្ឋនេះ។ អ្នកប្រមូលពន្ធម្នាក់ដែលត្រូវប្រមូលលុយដល់ទៅ $ 25,000,000 មិនព្រមសហការក្នុងការប្រាប់ពីប្រភពនៃលុយនោះទេ រហូតទាល់តែ Alex ចេញមកបង្ខំអ្នកយកពន្ធនេះដើម្បីធ្វើការសហការជាមួយនឹងក្រុមរបស់គាត់។

ភាពអាណាធិបតេយ្យបានកើតឡើងនៅក្នុងក្រុងរួមទាំងការបោកគ្រាប់បែកជាច្រើនកន្លែងនៅក្នុងក្រុងថែមទៀត។ អ្វីដែលលោកអ្នកត្រូវធ្វើគឺចាប់កាន់អាវុធ និងបង្ក្រាបក្រុមចលាចលទាំងអស់នោះជាមួយនឹងអាវុធពិសេសរបស់ពួកគេ។ លើសពីនេះទៀត វាថែមទាំងមានស្រោមមុខចំនួន 4 ប្រភេទសម្រាប់ក្រុមចចកមានដូចជា Hans, Trickster Demon, Dragon Head និង Viking។

PLAYDAY 2: WOLF PACK ក៏ផ្តល់នូវមុខងារពិសេស និងអស្ចារ្យជាច្រើនវគ្គកាន់តែសប្បាយរីករាយ និងអស្ចារ្យជាទីបំផុត។ លើសពីនោះ

ទៀត ប្រសិនបើលោកអ្នកអាចកម្ចាត់នូវក្រុមអាណាធិបតេយ្យទាំងអស់នោះបាន ក្រុមរបស់លោកអ្នកនឹងល្បីឈ្មោះហើយថែមទាំងបានឆ្លងទៅកាន់វគ្គអស្ចារ្យជាច្រើនទៀត។ តើនៅរង់ចាំអីទៀត តោះសាកល្បងហ្គេមបាញ់ប្រហារ PLAYDAY 2: WOLF PACK ទាំងអស់គ្នា៕

**ព័ត៌មានអំពីហ្គេម**

អ្នកអភិវឌ្ឍហ្គេម ៖ Overkill (Starbreeze Studio)
អ្នកចែកចាយ ៖ 505 Games
ថ្ងៃចេញផ្សាយ ៖ 12 កុម្ភៈ
ប្រភេទហ្គេម ៖ Action | Role Playing Games

**តម្រូវការប្រព័ន្ធ**

ប្រព័ន្ធប្រតិបត្តិការ ៖ Windows XP SP3 | Vista | Windows 7
អង្គប្រតិបត្តិការ ៖ 2.3 GHz Intel Quad Core Processor
មេម៉ូរី ៖ 3 GB RAM DDR3
ក្រាហ្វិកកាត ៖ NVIDIA GeForce GTX460 | ATI Radeon HD 5850
ទំហំថាសផ្ទុកទិន្នន័យ៖ 13 GB



Top Game

# XCOM 2

# សង្គ្រាមមនុស្សវិទ្យាសាស្ត្រ




XCOM® 2 ជាប្រភេទហ្គេមយុទ្ធសាស្ត្រស្ដីពីសង្គ្រាមវិទ្យាសាស្ត្រពីសំណាក់ក្រុម XCOM ដែលល្បីឈ្មោះបំផុតនៅក្នុងលោក។ 20 ឆ្នាំក្រោយពេលដែលមនុស្សលោកបានចាញ់សង្គ្រាមពីការឈ្លានពានរបស់ក្រុមមនុស្សភពផ្កាយ វាដល់ពេលដែលក្រុមបេសកកម្មពិសេស XCOM ទទួលបញ្ជាមកទាមទារផែនដីត្រលប់មកវិញពីមនុស្សភពផ្កាយទាំងអស់នោះ។

កងកម្លាំង XCOM មិនត្រឹមតែមានស្វាហាប់ និងខ្លាំងក្លាប៉ុណ្ណោះទេ ក្រុមនេះថែមទាំងទទួលភារកិច្ចដើម្បីកម្ចាត់នូវក្រុមភពផ្កាយទាំងអស់នោះថែមទៀត។ នៅសល់តែមនុស្សប៉ុន្មានក្រុមប៉ុណ្ណោះដែលបានរួចជីវិតចេញពីការឈ្លានពាននេះដោយសារតែចាញ់បោកក្រុមពិភពផ្កាយថានឹងកសាងពិភពលោកថ្មីជឿនលឿនបំផុត ប៉ុន្តែអ្វីៗគឺមិនពិតនោះទេ។

សម្ភារៈអាវុធទំនើបៗត្រូវបានប្រគល់ទៅឱ្យក្រុម XCOM ដើម្បីធ្វើការប្រកួតជាមួយនឹងក្រុមបិសាចភពផ្កាយទាំងអស់នោះ។ សង្គ្រាមវិទ្យាសាស្ត្រនឹងផ្ទុះឡើងទូទាំងពិភពលោកហើយការប្រយុទ្ធគ្នាលើកនេះពិតជាអស្ចារ្យញាក់សាច់ជាទីបំផុត។ តោះនៅចាំអីទៀត តើលោកអ្នកមានសមត្ថភាពគ្រប់គ្រាន់ដើម្បីកម្ចាត់នូវក្រុមបិសាចភពផ្កាយទាំងអស់នេះបានដែរឬទេ?



### ព័ត៌មានអំពីហ្គេម

អ្នកអភិវឌ្ឍហ្គេម ៖ Firaxis | Feral Interactive (Mac) | Feral Interactive (Linux)

អ្នកចែកចាយ ៖ 2K | Feral Interactive (Mac) | Feral Interactive (Linux)

ថ្ងៃចេញផ្សាយ ៖ 5 កុម្ភៈ

ប្រភេទហ្គេម ៖ Strategy

### តម្រូវការប្រព័ន្ធ

ប្រព័ន្ធប្រតិបត្តិការ ៖ Windows® 7 64-bit

អង្គប្រតិបត្តិការ ៖ 3GHz Quad Core

មេម៉ូរី ៖ 8 GB RAM DDR3

ក្រាហ្វិកកាត ៖ 2GB ATI Radeon HD 7970 | 2GB NVIDIA GeForce GTX 770

ទំហំថាសផ្ទុកទិន្នន័យ៖ 45 GB

New Software

# កម្មវិធីថ្មីៗ




## EximiousSoft Logo Designer អ្នកជំនាញរចនាឡូហ្គូ

EximiousSoft Logo Designer ជាកម្មវិធីដែលមានអនុភាពដោយបានផ្តល់នូវ Tools ជាច្រើនសម្រាប់ធ្វើការបង្កើតនូវរូបភាព Logos ដែលមានគុណភាពខ្ពស់ល្អសម្រាប់ប្រើប្រាស់នៅលើវេបសាយ ការបង្កើតស្លាក Banners ឬការធ្វើបទបង្ហាញនានា។ កម្មវិធីនេះអនុញ្ញាតឱ្យលោកអ្នកធ្វើការកំណត់ពណ៌ផ្ទៃ Background ការពង្រីកពង្រួមរូបភាព ឬការដាក់ចំណងជើងអក្សរផងដែរ។ លោកអ្នកអាចប្រើប្រាស់នូវ Tools សម្រាប់គូរជាច្រើនដូចជាបន្ទាត់ រង្វង់ ចតុកោណកែង ឬធ្វើការទាញយករូបភាពពីខាងក្រៅផងដែរ ហើយនៅពេលដែលកិច្ចការទាំងអស់នោះចប់រួចរាល់លោកអ្នកអាចធ្វើការ Export ទៅជា Files ប្រភេទ JPG, PNG, GIF, BMP, PCX, TIFF ឬ TGA ជាដើម។ លក្ខណៈពិសេសរបស់មួយគឺអាចធ្វើការបង្កើតរូបភាពច្រើនទម្រង់តាមការពេញចិត្ត មានរូបភាព Logo Templates ស្រាប់ៗច្រើនជាង 100 និងរូបសញ្ញាច្រើនជាង 5,000 រូប៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 22 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## Telegram ការទំនាក់ទំនងក្នុងល្បឿនលឿន និងជិតស្និទ្ធបំផុត

Telegram ជាកម្មវិធីផ្ញើសារដែលផ្តោតសំខាន់ទៅលើល្បឿននៃការបញ្ជូននៅលើអ៊ីនធឺណិត។ កម្មវិធីនេះមិនត្រឹមតែដំណើរការល្អឥតខ្ចោះនោះទេ ប៉ុន្តែវាងាយស្រួលប្រើប្រាស់ និងឥតគិតថ្លៃថែមទៀត។ កម្មវិធី Telegram ប្រើប្រាស់នូវ MTP ប្រូតូកូលដែលលោកអ្នកអាចធ្វើការបង្កើតនូវក្រុមសម្រាប់ Chat បានច្រើនរហូតទៅដល់ 200 នាក់។ អ្នកអាចធ្វើការចែករំលែកវីដេអូដែលមានទំហំក្រោម 1GB ឬការផ្ញើរូបភាពច្រើនសន្លឹកសន្ទាប់ចេញពីវេបសាយឬការផ្ញើរសារតបតដោយផ្ទាល់តែម្តង។សារទាំងអស់ត្រូវបានរក្សាទុកនៅលើ Cloud ហើយអ្នកអាចធ្វើការចូលទៅទាញយកបានគ្រប់ពេលវេលានៅពេលដែលអ្នកត្រូវការ។ លក្ខណៈពិសេសរបស់កម្មវិធីនេះមានដូចជា ការដំណើរការលឿន ការប្រើប្រាស់នូវ Cloud Storage គ្មានដែនកំណត់ ការប្រើប្រាស់នូវ Group Chat បានច្រើនសមាជិកដល់ទៅ 200 នាក់ ការផ្តល់នូវទំនុកចិត្ត 100%៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 16 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## TreeSize Free អ្នកជំនាញបង្ហាញព័ត៌មានលម្អិតនៃទិន្នន័យ

TreeSize Free ជាកម្មវិធីដែលមានប្រយោជន៍ក្នុងការរៀបចំនូវទំហំទំនេរនៅលើថាសផ្ទុកទិន្នន័យរបស់អ្នកដោយធ្វើការប្រាប់ពីចំនួនប្រើប្រាស់ដ៏ជាក់លាក់អំពីទំហំ Files ដែលរក្សាទុកនៅក្នុងកុំព្យូទ័ររបស់អ្នក។ កម្មវិធីនេះងាយស្រួលប្រើប្រាស់ព្រោះវាប្រាប់ពីទំហំរបស់ Folders ឬ Subfolders ផងដែរ។ ប្រសិនបើលោកអ្នកចង់មើលលម្អិតទៀតនោះគ្រាន់តែចុចនៅលើ Subfolders នោះវានឹងធ្វើការបង្ហាញពីទំហំទិន្នន័យទាំងអស់របស់អ្នក។ លក្ខណៈពិសេសសំខាន់ៗរបស់វាមានដូចជា ការដោះស្រាយទៅបញ្ហាផ្ទុកទិន្នន័យ ការគ្រប់គ្រងទំហំ Space នៅលើថាសផ្ទុកទិន្នន័យ និងព័ត៌មានលម្អិតនៃការផ្ទុកទិន្នន័យផងដែរ។ TreeSize Free អាចធ្វើការស្កេននូវលើ HDD ឬស្មាតហ្វូនរបស់អ្នកបានព្រោះវាប្រើប្រាស់នូវ MTP ប្រូតូកូល និង WebDAV ដែលអាចធ្វើការស្កេនផងដែរនៅលើបណ្តាញ Networks ឬ Cloud Drives ជាដើម៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 6 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## ConvertXtoDVD អស់បញ្ហាក្នុងការ Burn ទិន្នន័យទៅកាន់ DVD

ConvertXtoDVD ជាកម្មវិធីដែលមានភាពងាយស្រួលក្នុងការប្រើប្រាស់ដើម្បីធ្វើការបម្លែង ឬ Burn នូវវីដេអូរឿងរបស់លោកអ្នកទៅកាន់ DVD សម្រាប់ចាក់។ វាអាចធ្វើការទ្រទ្រង់បានច្រើន Formats ដូចជា DivX, Xvid, MOV, VOB, Mpeg, Mpeg4, AVI, WMV, DV ជាដើម។ ConvertXtoDVD មានភាពទាក់ទាញងាយស្រួលក្នុងការប្រើប្រាស់ មិនផ្តល់ភាពសាំញ៉ាំនោះទេ។ អ្វីដែលអ្នកត្រូវធ្វើគឺគ្រាន់តែធ្វើការបើកនូវវីដេអូ Files ដែលអ្នកចង់ធ្វើការបម្លែង រួចកំណត់នូវតម្រូវការមួយចំនួនតាមចិត្តរបស់អ្នកដូចជាការដាក់ពន្លឺ ការប្រើប្រាស់ Contrast ឬ Aspect Ratio ជាដើម បន្ទាប់មកចុចនៅត្រង់ពាក្យថា Convert ឬ Burn Files ទៅកាន់ DVD ជាការស្រេច។ លក្ខណៈពិសេសរបស់កម្មវិធីនេះគឺដំណើរការលឿន រហ័ស ផ្តល់នូវភាពងាយស្រួលក្នុងការប្រើប្រាស់ ការទ្រទ្រង់នូវ Audio ច្រើនទម្រង់ និងការជ្រើសរើសបានច្រើនភាសាផងដែរ៕




| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 50 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## ZoneAlarm Free Firewall របាំងការពារទិន្នន័យដ៏រឹងមាំពីក្រុម Hackers

ZoneAlarm Free Firewall ជាកម្មវិធីសម្រាប់ធ្វើការការពារខ្លួនពីក្រុម Hackers ដែលព្យាយាមវាយប្រហារមកកាន់កុំព្យូទ័ររបស់អ្នកព្រោះវាបានធ្វើការលាក់នូវ Traffic Network របស់អ្នក។ សមត្ថភាពក្នុងការការពារការវាយប្រហារនេះ ZoneAlarm Free Firewall ថែមទាំងជួយការពារកុំព្យូទ័ររបស់លោកអ្នកពីមេរោគដែលធ្វើឱ្យម៉ាស៊ីនកុំព្យូទ័រដំណើរការយឺតថែមទៀត ឬការការពារពីមេរោគដែលព្យាយាមចូលមកលួចយកនូវព័ត៌មានផ្ទាល់ខ្លួនដែលមានដូចជាលេខសម្ងាត់ ព័ត៌មានធនាគារជាដើម។ លក្ខណៈពិសេសរបស់កម្មវិធីនេះគឺ របាំងការពារដ៏រឹងមាំ ការកំបាំងខ្លួននៅលើអនឡាញ ទំហំតូចស្រាលមិនធ្ងន់ម៉ាស៊ីន ការកំណត់របាំងការពារពីការវាយប្រហារ ឬការប៉ុនប៉ងវាយប្រហារពីក្រុម Hackers ទុកជាមុន៕




| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 38 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## VideoPad Video Editor អ្នកឯកទេសកាត់តវីដេអូ

VideoPad Video Editor អនុញ្ញាតឱ្យលោកអ្នកធ្វើការកែប្រែទៅលើវីដេអូចេញពីការថតតាមកាមេរ៉ា ការថត DV ការថតតាម VHS ឬតាមរយៈ Webcam ជាដើម។ អ្នកអាចធ្វើការ Import នូវវីដេអូច្រើនទម្រង់ដូចជា avi, wmv, mpv និង divx ជាដើម។ កម្មវិធីនេះថែមទាំងបន្ថែមនូវ Transitions និង Visual Effects ឬការប្រើប្រាស់ Chroma Key Green Screen សម្រាប់ការផលិតវីដេអូជាដើម។ អ្នកអាចធ្វើការបង្កើត Files សម្រាប់ DVD, HD, YouTube ឬការ Burn ជាដើមដោយគ្មានបញ្ហា។ កម្មវិធីនេះផងដែរក៏អាចធ្វើការបង្កើតវីដេអូសម្រាប់ចាក់នៅលើអនឡាញ ឬដាក់នៅលើឧបករណ៍ស្មាតហ្វូនរបស់អ្នក។ លក្ខណៈពិសេសរបស់កម្មវិធីនេះគឺ ការចាប់ទាញ ទម្លាក់វីដេអូចូលគឺងាយស្រួលប្រើប្រាស់បំផុត ការបន្ថែមនូវ Effects/Transitions និងការបង្កើតវីដេអូតាមតម្រូវការសម្រាប់ប្រើប្រាស់នៅលើ DVD, HD ឬ YouTube ជាដើមនោះ៕




| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 5 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## Icecream Ebook Reader បណ្ណាល័យសៀវភៅដ៏អស្ចារ្យ

Icecream Ebook Reader អនុញ្ញាតឱ្យអ្នកប្រើប្រាស់ធ្វើការបន្ថែមនូវសៀវភៅបានច្រើនទៅកាន់កម្មវិធីមួយនេះដើម្បីធ្វើការបង្កើតនូវបណ្ណាល័យផ្ទាល់ខ្លួន។ អ្នកប្រើប្រាស់អាចធ្វើការដាក់កំណត់ចំណាំទៅលើសៀវភៅដែលពួកគេពេញចិត្ត ឬធ្វើការលុបសៀវភៅចេញពីបណ្ណាល័យរបស់ពួកគេបានយ៉ាងងាយស្រួល។ គ្រប់សៀវភៅនីមួយៗគឺតែងតែបង្ហាញនៅត្រង់ទំព័រដែលអ្នកប្រើប្រាស់បានអានចុងក្រោយគេបំផុត និងចំនួនភាគរយនៃការអានសៀវភៅនេះផងដែរ។ លក្ខណៈពិសេសរបស់កម្មវិធី Icecream Ebook Reader គឺអ្នកប្រើប្រាស់អាចធ្វើការស្វែងរកនូវឈ្មោះសៀវភៅ អ្នកនិពន្ធនៅក្នុងបណ្ណាល័យ ឬការស្វែងរកទំព័រជាក់លាក់នៅសៀវភៅនីមួយៗបានកាន់តែងាយស្រួលបំផុត។ កម្មវិធីនេះអាចប្រើប្រាស់បានជាមួយនឹងប្រភេទ Files ដូចជា epub, mobi, fb2, pdf, cbz និង cbr៕



| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 19 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## Sweet Home 3D

Sweet Home 3D ជាកម្មវិធីរចនាផ្ទៃកខាងក្នុងអាគារ ការិយាល័យ យានដ្ឋាន និងអគារជាច្រើនទៀតដែលអ្នកចង់បង្កើតឡើង។ វាមានលក្ខណៈល្អៗជាច្រើននៅក្នុងកម្មវិធី Sweet Home 3D នេះដូចជាការដាក់នូវគ្រឿងសង្ហារឹមនានានៅលើ 2D ប៉ុន្តែវាបង្ហាញជាទម្រង់ 3D ។ លក្ខណៈពិសេសរបស់កម្មវិធី Sweet Home 3D គឺការគូរបន្ទាត់ជញ្ជាំងកាន់តែងាយស្រួល ការដាក់ទ្វារ បង្អួច គ្រឿងសង្ហារឹមនានា ការផ្លាស់ប្តូរពណ៌ ការដាក់អក្សរ ការដាក់ទំហំក្រាស់ស្តើង ការដាក់ដំបូល ការគ្រប់គ្រងនូវភ្លើងនៅក្នុងបន្ទប់ ឬការកំណត់ទីតាំងអាគារ ការបន្ថែមនូវ Plug-ins និងការទ្រទ្រង់បាន 25 ភាសាថែមទៀតផង៕



| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 46 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## Iperius Backup អ្នកជំនាញក្នុងការ Backup ទិន្នន័យ

Iperius Backup ជាកម្មវិធីសម្រាប់ធ្វើការ Backup ទិន្នន័យដ៏មានប្រសិទ្ធិភាពនៅលើប្រព័ន្ធប្រតិបត្តិការ Windows សម្រាប់អ្នកប្រើប្រាស់ជាលក្ខណៈ Home Users ឬ Company Servers ជាដើម។ កម្មវិធីពិតជាអស្ចារ្យក្នុងការ Backup ដូចជា Drive Imaging, VSS, ការ Backup ទៅលើប្រព័ន្ធ Database (SQL Server, MySQL, MariaDB, PostgreSQL, Oracle), ការ Backup ទៅលើ Cloud (Google Drive, Amazon S3, OneDrive, Dropbox), FTP Backup (upload និង download), VMWare ESXi Backup (ការប្រើប្រាស់ Virtual Machines), Backup Tap (LTO, DAT) ឬការ Backup ទៅលើ NAS និង Synchronization ជាដើម។ លក្ខណៈពិសេសរបស់កម្មវិធី Iperius Backup អាចធ្វើការ Backup ដោយស្វ័យប្រវត្តិ ហើយវាថែមទាំងមានមិនធ្ងន់ម៉ាស៊ីន និងធ្វើការ Updates ដោយគ្មានបញ្ហា៕




| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 8 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## Mp3DirectCut

Mp3DirectCut ជាកម្មវិធីកែសម្លេងដែលដំណើរលឿន រហ័សទាន់ចិត្តហើយវាអាចធ្វើការ Compressed mp3 បានថែមទៀតផង។ អ្នកអាចធ្វើការកាត់សម្លេង ការកូពី ការផ្លាស់ប្តូរសំឡេងដោយគ្មានការប៉ះពាល់ទៅដល់សំឡេងដើមរបស់ Files mp3 របស់អ្នកនោះទេ។ លក្ខណៈពិសេសរបស់កម្មវិធី Mp3 DirectCut នេះគឺគ្មានការខូចខាតដល់ទិន្នន័យដើម ការកែប្រែសំឡេងបានលឿនបំផុត និងមុខងារពិសេសៗជាច្រើនទៀត។ កម្មវិធីនេះចំណេញពេលវេលាក្នុងការកាត់ ហើយវាថែមទាំងផ្តល់នូវវីដេអូដែលមានគុណភាពខ្ពស់ថែមទៀតផង៕



| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 300 KB | គ្រប់ Windows | www.itcity.com.kh | បានរហូត |



# DYING LIGHT THE FOLLOWING ENHANCED EDITION តាមកម្ចាត់ពន្លឺមរណៈ

DYING LIGHT THE FOLLOWING ENHANCED EDITION ជាហ្គេមស៊េរីថ្មីដែលត្រូវបានអភិវឌ្ឍ និងចេញផ្សាយក្រោមស្លាកឈ្មោះរបស់ Techland ។ វគ្គថ្មីនេះនិយាយពីសង្គ្រាមរបស់បិសាច Zombie ដែលចូលមកវាយលុកពិភពលោកទាំងមូលដើម្បីកាន់កាប់តែម្តងដោយថាមពលអាថ៌កំបាំងបំផុត។ អ្វីដែលអ្នកត្រូវប្រុងប្រយ័ត្នបំផុតនោះគឺនៅពេលរាត្រីដែលចូលមកដល់ ព្រោះចំនួននៃខ្មោច Zombies មានចំនួនច្រើនលើសលប់ ហើយថែមទាំងមានកម្លាំងខ្លាំងក្លាបំផុត។

វគ្គថ្មី ENHANCED EDITION នេះបានដាក់បញ្ចូលនូវ Be The Zombie, Ultimate Survivor Bundle, The Bozak Horde និង Cuisine & Cargo ដែលសុទ្ធតែជាវគ្គប្លែកខុសពីមុន។ អ្វីដែលកាន់តែពិសេសជាងនេះទៀត អាវុធជាច្រើនប្រភេទត្រូវបានដាក់បញ្ចូលនៅក្នុងហ្គេមនេះ ហើយនឹងការដោះចំណោទប្រស្នាលំបាកៗជាច្រើនផងដែរ។ ការធ្វើដំណើរនៅក្នុងសាច់រឿងនេះពិតជាផ្សងព្រេង និងគ្រោះថ្នាក់ជាទីបំផុតដែលលោកអ្នកនឹកស្មានមិនដល់។

DYING LIGHT THE FOLLOWING គឺពិតជាហ្គេមរត់គេច និងការប្រយុទ្ធយ៉ាងរន្ធត់ និងជក់ចិត្តជាទីបំផុត។ ការប្រើប្រាស់កាំភ្លើង ឬអាវុធជាច្រើនទៀតត្រូវទាមទារនូវភាពស្ទាត់ជំនាញផងដែរព្រោះចំនួននៃខ្មោច Zombies គឺច្រើនហើយថែមទាំងមានកម្លាំងទ្វេដងថែមទៀត។ វាពិតជាសប្បាយញាប់ញ័រ និងប្លែកពីហ្គេមនានា។ តើលោកអ្នកអាចកម្ចាត់នូវខ្មោច បិសាចទាំងអស់នេះបានដែរឬទេ?

**ព័ត៌មានអំពីហ្គេម**

អ្នកអភិវឌ្ឍហ្គេម ៖ Techland អ្នកចែកចាយ៖ Techland

ប្រភេទហ្គេម ៖ Action | Role Playing Games

**តម្រូវការប្រព័ន្ធ**

ប្រព័ន្ធប្រតិបត្តិការ ៖ Windows® 7 64-bit / Windows® 8 64-bit / Windows® 8.1 64-bit

អង្គប្រតិបត្តិការ ៖ Intel® Core™ i5-4670K @3.4 GHz / AMD FX-8350 @4.0 GHz

មេម៉ូរី ៖ 8 GB RAM DDR3

ក្រាហ្វិកកាត ៖ NVIDIA® GeForce® GTX 780 / AMD Radeon™ R9 290 (2GB VRAM)

ទំហំថាសផ្ទុកទិន្នន័យ៖ 40 GB




# SOCCER MANAGER 2016 កំពូលគ្រូបង្វឹកបាល់ទាត់រដូវកាលថ្មី

ស្វាគមន៍មកកាន់ហ្គេម SOCCER MANAGER 2016 ដែលជាពិភពប្រមូលផ្តុំនូវគ្រូបង្វឹកល្បីៗនៅលើពិភពលោកដែលមានជំនាញក្នុងការដឹកនាំក្លឹបធំៗ និងល្បីឈ្មោះជាយូរឆ្នាំមកហើយ។ អ្វីដែលកាន់តែប្លែកសម្រាប់ហ្គេមនេះគឺលោកអ្នកអាចលេងបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែងជាមួយនឹងជើងខ្លាំងជាច្រើននាក់នៅជុំវិញពិភពលោក ហើយក្លឹបសរុបនៅក្នុងហ្គេមនេះមានប្រមាណជា 750 ក្លឹបរបស់ 48 លីគកំពូលក្នុងពិភពលោក។

ភារកិច្ចរបស់អ្នកគឺត្រូវទិញ លក់កីឡាករ ដើម្បីធ្វើការពង្រឹងនូវសមត្ថភាពរបស់ក្លឹប ក៏ដូចជាការស្វែងរកពានរង្វាន់ជាច្រើនសម្រាប់ក្រុមរបស់លោកអ្នក។ កីឡាករសរុបទាំងអស់របស់ហ្គេម SOCCER MANAGER 2016 មានប្រមាណជា 70,000 នាក់ហើយលោកអ្នកអាចទស្សនានូវការប្រកួតរបស់ក្រុមលោកអ្នកបានថែមទៀត។

មួយវិញទៀត ការប្រកួតជាមធ្យមគឺ 2 ទៅ 3 ប្រកួតក្នុងមួយសប្តាហ៍ជាមួយនឹងក្លឹបផ្សេងទៀត។ គ្រប់ការប្រកួតទាំងអស់ពិតជាស្វិតស្វាញបំផុត ដូចនេះលោកអ្នកត្រូវតែស្វែងរកយុទ្ធសាស្ត្រតាកទិច ឬតិចនិកថ្មីៗដើម្បីជួយក្លឹបរបស់លោកអ្នកឈ្នះការប្រកួតនេះ។ នៅពេលដែលដល់រដូវកាលទិញលក់កីឡាករ គ្រូបង្វឹកជាអ្នកសម្រេចចិត្តក្នុងការដោះដូរកីឡាករជាមួយនឹងក្លឹបផ្សេង។ តោះសាកល្បងហ្គេម SOCCER MANAGER 2016 តើវាមានអ្វីដែលថ្មីខ្លះ?

### ព័ត៌មានអំពីហ្គេម

| | |
|---|---|
| អ្នកអភិវឌ្ឍហ្គេម | ៖ Soccer Manager Ltd |
| អ្នកចែកចាយ | ៖ Soccer Manager Ltd |
| ថ្ងៃចេញផ្សាយ | ៖ 9 កុម្ភៈ |
| ប្រភេទហ្គេម | ៖ Sports I Strategy I Simulation |

### តម្រូវការប្រព័ន្ធ

| | |
|---|---|
| ប្រព័ន្ធប្រតិបត្តិការ | ៖ Windows XP, Vista, 7, 8 |
| អង្គប្រតិបត្តិការ | ៖ Intel Pentium 4 I Intel Core I AMD Athlon |
| មេម៉ូរី | ៖ 2 GB RAM DDR3 |
| ក្រាហ្វិកកាត | ៖ NVidia GeForce FX 5900 Ultra, ATI Radeon 9800, Intel GMA X3100 - 128MB VRAM |
| ថាសផ្ទុកទិន្នន័យ | ៖ 5 GB |




# ស្វែងយល់ពីគន្លឹះផ្សេងៗ ក្នុងការប្រើប្រាស់កុំព្យូទ័រ

## វិធីងាយៗក្នុងការបំលែង File PDF ឱ្យក្លាយជា Word Document

# វិធីងាយៗក្នុងការបំលែង File PDF ឱ្យក្លាយជា Word Document




ចំពោះឯកសារប្រភេទ PDFs គឺជាឯកសារដែលមានភាពងាយស្រួលក្នុងការចូលមើល និងបង្ហាញ ប៉ុន្តែអ្នកពុំអាចមានលទ្ធភាពក្នុងការកែប្រែ ឬបន្ថែមន័យសេចក្តីអ្វីទៀតនោះឡើយ។ យ៉ាងណាមិញក៏មានវិធីសាស្រ្តមួយចំនួនដើម្បីឲ្យអ្នកអាចឱ្យអ្នកបំលែងឯកសាររបស់អ្នកបានពី file ប្រភេទ PDFs ទៅកាន់ file ប្រភេទ word document ដោយគ្រាន់តែធ្វើតាមសេចក្តីណែនាំតាមលំដាប់លំដោយខាងក្រោមនេះ ៖

## វិធីសាស្រ្តទី 1: ប្រើប្រាស់ Google Docs

Sign in ទៅកាន់ Google account របស់អ្នករួចចូលទៅកាន់ Google Docs ដោយអ្នកគ្រាន់តែចុច លើសញ្ញា ⋮⋮⋮ រួច click លើប៊ូតុងដូចរូបខាងក្រោម។




រួចចុចលើប៊ូតុងដូចរូបខាងក្រោម។



បន្ទាប់មកទៀតចុចលើប៊ូតុង Upload បន្ទាប់មក Browse ទៅរកទីតាំងនៃឯកសារដែលអ្នកចង់ធ្វើការ Upload ដើម្បីធ្វើការបំលែង។




រង់ចាំរហូតការ Upload ឯកសាររបស់អ្នកត្រូវបានបញ្ចប់។




បន្តចូលទៅកាន់ Google Drive account របស់អ្នកនោះអ្នកនឹងឃើញមាន file PDF ដែលអ្នកទើបនឹងបាន Upload ចូល។ ក្នុងពេលនេះ ចូរអ្នកចុច Mouse ខាងស្តាំទៅលើ file នោះរួចជ្រើសរើសយក ពាក្យ "Open with" និង select យកពាក្យ "Google Docs"។




នៅពេលដែល file បានបើកដំណើរការនៅក្នុង Google Docs នោះ ចូរអ្នកចុចលើមីនុយ "File" រួចជ្រើសរើសយកពាក្យ "Download as" ហើយ select យកពាក្យ "Microsoft Word (docx)" ។




## វិធីសាស្ត្រទី 2: បំលែងនៅលើវិបសាយអីនធឺណេត

ចូលទៅកាន់ប្រអប់ស្វែងរករបស់ Google រួចវាយពាក្យថា 'online pdf to word convertor' នោះអ្នកនឹងឃើញមានការបំលែងឯកសារ Online ដោយមិនចាំបាច់ដោនឡូត Software អ្វីនោះទេ។ រួចជ្រើសរើសវិបសាយណាមួយដែលអ្នកគិតថាងាយស្រួលសម្រាប់អ្នក។




ចូរចុចលើប៊ូតុង select your file។




Select ឯកសារ PDF ណាមួយចេញពីកុំព្យូទ័រអ្នកដើម្បីធ្វើការបំលែង។




បញ្ចូលអ៊ីម៉ែលរបស់អ្នកប្រសិនបើមានការទាមទារ




ប៉ុន្តែអាចមានវិបសាយមួយចំនួនសុំឱ្យអ្នកបំពេញលេខកូដដើម្បីធ្វើការបញ្ជាក់បន្ថែមឱ្យកាន់តែច្បាស់។




ចុចប៊ូតុង Convert Now។



រង់ចាំរហូតដល់ឯកសាររបស់អ្នកបំលែងរួចរាល់។




នៅពេលដែល file នោះត្រូវបានបំលែងចប់ អ្នកអាចចូលទៅទាញយកបាននៅក្នុងអ៊ីម៉ែលរបស់អ្នក។




## វិធីសាស្ត្រទី 3: បំលែងនៅក្នុងកម្មវិធី Adobe Acrobat

បើកកម្មវិធី Adobe Acrobat ឱ្យដំណើរការ។




ចុចលើ File។




ជ្រើសរើសពាក្យថា Open។



ស្វែងរកឯកសារណាមួយដែលអ្នកចង់បំលែងទៅកាន់ Word Doc។




## ចាប់ផ្តើមបំលែងជាមួយនឹងរបៀបពីរផ្សេងគ្នា

ចុចលើ Tab File រួចជ្រើសរើសយក Save As បន្ទាប់មកធ្វើការ select ប្រភេទនៃឯកសារ «Format» និងជាចុងក្រោយចូរជ្រើសរើស «Microsoft Word Document.»។

Click លើ Tab File ដូចគ្នា ប៉ុន្តែជ្រើសរើសយកពាក្យថា Export មិនមែន Save As នោះទេ ហើយបន្ទាប់មកទៀតចូរ select ពាក្យថា «Word Document.» រួចចុច Save ជាការស្រេច។




រង់ចាំរហូតដល់ការបំលែងត្រូវបានបញ្ចប់។




ឯកសារ Word Doc ថ្មីគួរតែស្ថិតនៅទីតាំងជាមួយគ្នានឹង File ដែលអ្នកបំលែង (លុះត្រាតែអ្នកដូរទីតាំងរបស់វា)។





# មេរោគកុំព្យូទ័រទាំង 5 ដែលមានឥទ្ធិពលខ្លាំងក្លា និងគ្រោះថ្នាក់បំផុត

មេរោគនៅលើកុំព្យូទ័របានក្លាយទៅជារឿងដែលគ្រោះថ្នាក់បំផុត និងបង្កបញ្ហាយ៉ាងខ្លាំងទៅលើឧបករណ៍ដែលលោកអ្នកកំពុងតែប្រើប្រាស់។ វាអាចធ្វើការបិទនូវប្រព័ន្ធប្រតិបត្តិការ និងដំណើរការរបស់ប្រព័ន្ធ System ហើយវាអាចធ្វើការបំផ្លាញនូវឯកសារដែលលោកអ្នកមាននៅក្នុង Hard Disk របស់អ្នកបានថែមទៀតផង។

តើអ្វីទៅដែលជាមេរោគកុំព្យូទ័រ? មេរោគកុំព្យូទ័រជាប្រភេទ Malware ដែលអាចដំណើរការ និងបង្កើតទីតាំងលាក់ខ្លួនដោយខ្លួនឯងស្វ័យប្រវត្តិ (នៅពេលដែលមានអ្នកប្រើប្រាស់ចុចលើវា) នៅក្នុងកម្មវិធីកុំព្យូទ័ររបស់អ្នក ឬនៅក្នុងឯកសាររបស់អ្នក ឬនៅក្នុង Boot Sector របស់ Hard Drive របស់អ្នកជាដើម។ នៅពេលដែលវាបានដំណើរការយ៉ាងជោគជ័យនៅក្នុងប្រព័ន្ធ System របស់អ្នកទាំងមូល គ្រប់ផ្នែកទាំងអស់នៅក្នុងកុំព្យូទ័រត្រូវបានឆ្លងមេរោគ និងគ្រប់គ្រងដោយមេរោគ។

ខណៈពេលដែលមនុស្សទូទៅអាចធ្វើការសរសេរកូដបង្កើតមេរោគបាន ជាពិសេសក្រុម Hackers ដែលចូលចិត្តសរសេរកូដដើម្បីធ្វើការបង្កើតនូវមេរោគទាំងនេះ។ មួយវិញទៀត ក្រុម Hackers ខ្លះបានធ្វើការបង្កើតនូវមេរោគដែលភ្ជាប់ជាមួយនឹងកម្មវិធីប្រើប្រាស់តែម្តង ហើយវាត្រូវបានតម្លើងនៅក្នុង System របស់កុំព្យូទ័របន្ទាប់មកមេរោគទាំងនោះបានជ្រាតចូលទៅក្នុងកុំព្យូទ័រតែម្តង។

បច្ចុប្បន្ននេះ អ្នកប្រើប្រាស់មួយចំនួនធំនៅមិនទាន់ស្គាល់ច្បាស់ពីប្រភេទនៃមេរោគនោះទេ។ ខាងក្រោមនេះជាមេរោគកុំព្យូទ័រទាំង 5 ដែលគ្រោះថ្នាក់បំផុត និងជះឥទ្ធិពលលឿននៅក្នុងប្រព័ន្ធកុំព្យូទ័រទាំងមូលរបស់អ្នក។

## មេរោគ ILOVEYOU

មេរោគនេះប្រហែលជាគ្រោះថ្នាក់បំផុតនៅលើម៉ាស៊ីនកុំព្យូទ័ររបស់អ្នកដែលបង្កើតឡើងមកមានទម្រង់ដូចជា Worm ព្រោះវាអាចដំណើរការដោយខ្លួនឯងបាន។ មេរោគ ILOVEYOU នេះឆ្លងតាមប្រភពពីប្រព័ន្ធអ៊ីនធឺណិតតាមរយៈអ៊ីម៉ែល ហើយវាមានសមត្ថភាពអាចអាចធ្វើការបំផ្លាញកុំព្យូទ័រជាច្រើននៅលើពិភពលោក។ ដើម្បីធ្វើឱ្យលោកអ្នកអាចចុចនៅលើមេរោគនេះបាន ប្រធានបទដែលមេរោគនេះបានផ្ញើរចូលមកក្នុងកុំព្យូទ័ររបស់អ្នកនោះគឺជាសារស្នេហាដែលបញ្ជូនមកពីជនមិនស្គាល់មុខ។ ក្នុងនោះមាន File សម្រាប់ធ្វើការ Attach ភ្ជាប់មកនៅក្នុងម៉ែលរួចជាស្រេច ប្រសិនបើលោកអ្នកចុចនៅឯកសារនេះនោះលោកអ្នកប្រាកដជាមានបញ្ហាជាក់ជាមិនខាន។ ឯកសារដែលភ្ជាប់មកនៅក្នុងអ៊ីម៉ែលមានឈ្មោះថា LOVE-LETTER-FOR-YOU.TXT.vbs ។ នៅពេលដែលអ្នកចុចបើកឯកសារនេះ មេរោគនេះនឹងឆ្លងចូលភ្លាមទៅកាន់កុំព្យូទ័ររបស់អ្នក។ មេរោគនេះបានបំផ្លាញនូវទិន្នន័យក្នុងរង្វង់ទឹកប្រាក់ជាង 15 ពាន់លានដុល្លារអាមេរិចហើយវាថែមទាំងជះឥទ្ធិពលខ្លាំងប្រមាណជា 10% នៅលើកុំព្យូទ័រទូទាំងពិភពលោកដែលបានភ្ជាប់ទៅកាន់អ៊ីនធឺណិត។

## មេរោគ Melissa

Melissa ជាមេរោគដែលមានទំហំរូបរាងតូចដែលទទួលឈ្មោះល្បីល្បាញ និងគ្រោះថ្នាក់បំផុតនៅលើពិភពលោកហើយឈ្មោះរបស់វាគឺល្បីតាំងតែពីថ្ងៃទី 26 មីនា ឆ្នាំ 1999។ មេរោគតូចមួយនេះត្រូវបានបង្កើតឡើងដោយ David L ដែលត្រូវបានភ្ជាប់ជាមួយនឹងអ៊ីម៉ែលហើយវាមានឈ្មោះថា "list.doc" ហើយនៅពេលដែលអ្នកប្រើប្រាស់ចុច Click ទៅលើទិន្នន័យ Attachment នេះ មេរោគនេះនឹងដំណើរការភ្លាមចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រហើយវានឹងធ្វើការចូលទៅកាន់ Microsoft Outlook ដើម្បីធ្វើការស្វែងរកនូវ Contacts Address រួចបញ្ជូនទៅកាន់អ៊ីម៉ែលរបស់បញ្ជីឈ្មោះ 50 នាក់ដំបូងដោយភ្ជាប់ជាមួយនឹងសារថា "នេះជាឯកសារដែលលោកអ្នកកំពុងតែស្វែងរក កុំប្រាប់អ្នកណាផ្សេងពីរឿងនេះឱ្យសោះ!" ក្រោយមក ប៉ូលីស FBI បានចាប់ខ្លួនលោក David L និងបានពិន័យទឹកប្រាក់ 5,000 ដុល្លារអាមេរិចដោយសារតែបង្កើតមេរោគនេះ។

# មេរោគ My Doom

My Doom ត្រូវបានគេរកឃើញជាប្រភេទ Malware ដែលមានគ្រោះថ្នាក់បំផុតនៅលើពិភពលោកនៅថ្ងៃទី 26 មករា 2004 ហើយត្រូវបានសាយភាសពាសពេញពិភពលោកតាមរយៈការបញ្ជូន Random នៅលើអ៊ីម៉ែល។ ភាពខ្លាំងក្លារបស់ My Doom គឺវាបានធ្វើការបំផ្លាញបិទនូវប្រព័ន្ធដំណើរការរបស់កុំព្យូទ័រជាង 2 លានគ្រឿងតាមរយៈការវាយប្រហារតាម Service Attack។ វាបានបញ្ជូនខ្លួនវាតាមរយៈអ៊ីម៉ែលដោយភ្ជាប់ជាមួយនឹងសារព្រមានថា "Mail Transaction Failed" ។ ប៉ុន្តែប្រសិនបើអ្នកប្រើប្រាស់ហ៊ានតែធ្វើការចុច Click ទៅលើតំណរនេះ File Attachment នឹងធ្វើការដំណើរការ ហើយមេរោគនេះនឹងធ្វើការស្វែងរកនូវបញ្ជីឈ្មោះដែលរក្សាទុកនៅក្នុងកុំព្យូទ័រហើយបញ្ជូនអ៊ីម៉ែលបន្តទៅកាន់អ្នកផ្សេងទៀត។ ការបំផ្លាញទិន្នន័យតាមរយៈមេរោគ My Doom គិតជាទំហំសាច់ប្រាក់ប្រមាណជា 38 ពាន់លានដុល្លារអាមេរិច។

# មេរោគ Sasser

មេរោគ Sasser ត្រូវបានបង្ហាញខ្លួននៅក្នុងឆ្នាំ 2004 ហើយវាឆ្លងនៅលើប្រព័ន្ធប្រតិបត្តិការ Windows OS ហើយវាបានធ្វើការបំផ្លាញទិន្នន័យជាច្រើនរបស់អ្នកប្រើប្រាស់។ វាមិនធ្វើការឆ្លងតាមរយៈការបញ្ជូនតាមអ៊ីម៉ែលនោះទេដូចមេរោគផ្សេងនោះទេ។ នៅពេលដែលកុំព្យូទ័រឆ្លងមេរោគនេះ វានឹងធ្វើការចូលទៅវាយលុក System ដោយធ្វើការទាញយកនូវមេរោគជាច្រើនចូលមកបន្ថែមទៀត។ មេរោគនេះធ្វើការស្កេននូវ IP Address ហើយជ្រាតចូលក្នុងកុំព្យូទ័ររបស់ជនរងគ្រោះតែម្តង។ មេរោគនេះនឹងធ្វើកែកែប្រែនូវ System របស់ជនរងគ្រោះទាំងមូល ហើយបើទោះជាបីជាជនរងគ្រោះផ្តាច់ភ្លើងក៏អ្វីគ្រប់យ៉ាងមិនអាចបញ្ឈប់សកម្មភាពរបស់វាបានដែរ។ មុខងាររបស់មេរោគ Sasser គឺធ្វើការគ្រប់គ្រងត្រង់ផ្នែក Local Security Authority Subsystem Service ទាំងមូលរបស់ប្រព័ន្ធកុំព្យូទ័រ។ មេរោគនេះអាចជ្រៀតចូលទៅក្នុងការវិស័យធំៗជាច្រើនដូចជា មន្ទីរពេទ្យ មធ្យោបាយធ្វើដំណើរសាធារណៈ ប្រព័ន្ធលកអាកាស ប្រព័ន្ធសារព័ត៌មាន និងជាច្រើនទៀត។ បន្ទាប់ពីរងគ្រោះរាប់លាននាក់កន្លងមក រង្វង់ទឹកប្រាក់ដែលខូចខាតដោយសារមេរោគនេះមានខ្ទង់ប្រមាណជា 18 ពាន់លានដុល្លារអាមេរិច៕

# មេរោគ Code Red

មេរោគនេះត្រូវបានបង្ហាញខ្លួននៅចុងឆ្នាំ 2001 ដែលធ្វើការឆ្លងតាមរយៈ Microsoft Internet Information Server ។ រយៈពេលប៉ុន្មានខែចុងក្រោយនេះ មេរោគជាច្រើនត្រូវបានបង្ហាញខ្លួននៅលើអ៊ីនធឺណិត ហើយអ្វីដែលសំខាន់នោះគឺពេលខ្លះអ្នកប្រើប្រាស់មិនបានចុចនៅលើ Attachment File មែន ប៉ុន្តែវាបានសរសេរភ្ជាប់ជាមួយនឹងកម្មវិធីប្រើប្រាស់ទៅវិញ។ អ្នកអាចធ្វើការសំគាល់នូវមេរោគនេះបាននៅពេលដែលលោកអ្នកធ្វើការចូលទៅបើកអ៊ីនធឺណិត វានឹងធ្វើការបញ្ជូនសារទៅកាន់ Web Page របស់អ្នកថា "Hacked by Chinese!" ។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺថា ត្រឹមតែរយៈពេលតិចជាង 1 សប្តាហ៍ មេរោគ "Code Red" បានធ្វើការឆ្លងចូល 400,000 Servers ដែលមានទាំង Web Server របស់ White House ផងដែរ។ មេរោគនេះបានបំផ្លាញទិន្នន័យក្នុងរង្វង់ទឹកប្រាក់ប្រមាណជា 2.6 ពាន់លានដុល្លារអាមេរិចហើយវាបានឆ្លងចូលកុំព្យូទ័រច្រើនជាង 1 លានគ្រឿង។

## មេរោគ ILoveyou

បំផ្លាញទិន្នន័យក្នុងរង្វង់ទឹកប្រាក់

$ 15,000,000,000

ឆ្លងចូលកុំព្យូទ័រច្រើនជាង

500,000 គ្រឿង

## មេរោគ Melissa

បង្កើតឡើងនៅ

ថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៩៩

## មេរោគ My Doom

បំផ្លាញទិន្នន័យក្នុងរង្វង់ទឹកប្រាក់

$ 38,000,000,000

ឆ្លងចូលកុំព្យូទ័រច្រើនជាង

2,000,000 គ្រឿង

## មេរោគ Sasser

បំផ្លាញទិន្នន័យក្នុងរង្វង់ទឹកប្រាក់

$ 18,000,000,000

ឆ្លងចូលកុំព្យូទ័រច្រើនជាង

1,000,000 គ្រឿង

## មេរោគ Code Red

បំផ្លាញទិន្នន័យក្នុងរង្វង់ទឹកប្រាក់

$ 2,600,000,000

ឆ្លងចូលកុំព្យូទ័រច្រើនជាង

1,000,000 គ្រឿង

Graphic




# បង្កើត icon របស់ Apple Watch App ជាមួយនឹង illustrator

លោកអ្នកអាចធ្វើការបង្កើតនូវ icons នីមួយៗសម្រាប់ Apple Watch App ដែលអាចមើលឃើញនៅលើ Apple Watch Home Screen។ យើងអាចប្រើប្រាស់ Shapes ដែលជាមូលដ្ឋាន និង Wrap Effects ដើម្បីធ្វើការរចនាតាមវិធីសាស្ត្រដែលធ្វើឱ្យរូបភាពកាន់តែទាន់សម័យ។

## 1. Apple Watch Icon Guidelines

លោកអ្នកអាចដោនឡូត ពុម្ពគំរូដើម្បីងាយស្រួលក្នុងការរចនារូបរាងរបស់វាតាមរយៈ https://github.com/iconfinder/apple-watch-icons/archive/master.zip ។

## 2. Create the Time, Mail and Music App Icons

### ជំហានទី 1

លោកអ្នកអាចចាប់ផ្តើមដំបូងជាមួយគំរូ icon មួយ (ក្នុងការបង្រៀននេះប្រើប្រាស់គំរូ icon សម្រាប់នាឡិកា 38 mm)។ សូមចូលទៅកាន់ View > Hide Grid ដើម្បីលុបបំបាត់ក្រឡាបន្ទាត់ ប៉ុន្តែអ្នកត្រូវប្រាកដថាបានបើក Smart Guides និង Snapping (លោកអ្នកអាចស្វែងរកពួកគេនៅក្នុងម៉ឺនុយដូចគ្នា ដើម្បីងាយស្រួលធ្វើការជាមួយវា។




### ជំហានទី 2

បង្កើត icon ដំបូងជាមួយ Time app ដោយប្រើរង្វង់ទំហំ 4 x 4 px នៅផ្នែកកណ្តាលនៃពុម្ពគំរូ បន្ទាប់មកចុចពីរដងនៅលើ Ellipse Tool (L) ដើម្បីបើកប្រអប់ដែលត្រូវជ្រើសរើស បន្ទាប់មកទៀតប្រើ Align panel ដើម្បីដាក់រង្វង់បញ្ឈរ និងផ្តេកនៅលើ Artboard បំពេញពណ៌រង្វង់ដោយពណ៌ទឹកក្រូច (#FF9506)។




### ជំហានទី 3

ប្រើ Rectangle Tool (M) ដើម្បីបង្កើតទំហំ 2 x 40 px ទីពីររបស់នាឡិកា ហើយត្រូវប្រើពណ៌ដូចគ្នាដែរ បន្ទាប់មកដាក់ទីតាំងវាឱ្យស្ថិតនៅកណ្តាលដូចបង្ហាញក្នុងរូបភាពខាងក្រោម។



លោកអ្នកអាច align ដោយផ្ទាល់ to the Key Object ដោយការចុចលើរង្វង់កំឡុងពេលដែលចុច Alt key ។




## ជំហានទី 4

ចាប់ផ្តើមចំលងទ្រនិចទីពីរ ហើយធ្វើវាឱ្យខ្លីជាងមុន បន្ទាប់មកបង្វិលវា -60 degrees ដោយដាក់វាតាមទីតាំង Guide ដូចក្នុងរូបដែលបានបង្ហាញ ។



ឥលូវនេះធ្វើទំរង់ទ្រនិចនាទី ដោយបង្កើតនូវចតុកោណកែងពណ៌ខ្មៅប្រវែង 4 x 30 px ហើយប្រើមុខងារ Live Corners ដើម្បីបង្កើតនៅជុំវិញចុងទាំងសងខាងដោយរង្វង់តូចជាមួយ Direct Selection Tool (A) ធំបំផុតត្រឹម (2 px ជ្រុងកំណោង)។




## ជំហានទី 5

ចូរដាក់វានៅត្រង់ទីតាំងសក្តិសម (លោកអ្នកអាចបង្កើតឱ្យតូចបន្តិចដែលត្រូវជាមួយរង្វង់នៅខាងក្នុងនៃ icon base)។



## ជំហានទី 6

បង្កើតចតុកោណកែងផ្សេងទៀតដែលមានទំហំ 4 x 20 px សម្រាប់នាឡិកាដៃ។ ធ្វើការបង្វិល 60 degrees និងដាក់វានៅទីតាំងផ្ទុយគ្នាពីទ្រនិចនាទី។










## ជំហានទី 7

ជាចុងក្រោយបង្កើតរូបអេលីបពណ៌សទំហំ 80 x 80 px ជាមួយ Ellipse Tool (L) សម្រាប់ icon base និងទីតាំងដែលមិនសមទាំងអស់របស់ objects ផ្សេងទៀត។ ពេលនេះចំពោះរូប icon ដំបូងរបស់យើងគឺរួចរាល់ហើយ ចាប់ផ្តើមទៅរូបបន្ទាប់។

## ជំហានទី 8

ឥលូវយើងធ្វើការបង្កើតនូវ Mail icon ដោយចាប់ធ្វើពីការបង្កើតរូបចតុកោណកែងប្រវែង 50 x 33 px នៃពណ៌មួយចំនួន។




បន្ថែមត្រីកោណទំហំ 2 pt Stroke ដោយប្រើប្រាស់ Polygon Tool ជាមួយតម្លៃ 3 Sides ជាមួយ Pen Tool (P)។ គ្រាន់តែចូលទៅកាន់ Object > Expand ធ្វើត្រីកោណនេះដើម្បីផ្លាស់ទីវាទៅក្នុងបន្ទាត់កោង។




## ជំហានទី 9

បន្ថែមត្រីកោណទៅលើផ្នែកខាងលើនៃទីតាំងដែលបិទជិតធ្វើវាឱ្យទាបជាងជ្រុងនៅជុំវិញ ហើយពង្រីករូបរាង។ លោកអ្នកអាចលុបបំបាត់ផ្នែកខាងលើនិងខាងក្រោមនៃត្រីកោណជាមួយ Eraser Tool (Shift-E) នូវផ្នែកដែលយើងមិនត្រូវការវា។





លុបផ្នែកខាងលើនៃត្រីកោណដែលទាបជាងគេជាមួយ Eraser Tool (Shift-E) និង Unite ផ្នែកទាំងពីរនៃត្រីកោណក្នុង Pathfinder។ ជាចុងក្រោយ ធ្វើការចំលងរូបរាងជាមូលដ្ឋានដែលបិទជិត (Control-C > Control-F) ជ្រើសរើសចតុកោណកែងទាំងពីរ និងទម្រង់ផ្នែកខាងលើ ហើយប្រើមុខងារ Intersect នៃ Pathfinder ដើម្បីកាត់ផ្នែកខាងក្រៅ។






## ជំហានទី 10

ធ្វើការជ្រើសរើសចតុកោណកែង ហើយធ្វើឱ្យមានស្នាមឆ្នូតម្តងទៀត និងប្រើមុខងារ Minus Front នៃ Pathfinder ដើម្បីកាត់បន្ទាត់ចេញ។ ធ្វើការផ្លាស់ប្តូរពណ៌ស្រោមសំបុត្រទៅជាពណ៌ស និងបន្ថែមរូបរង្វង់សម្រាប់ icon ដោយបំពេញវាជាមួយបន្ទាត់ទ្រេតពីពណ៌ខៀវចាស់ (#2066F0) នៅផ្នែកខាងលើទៅជាពណ៌ខៀវភ្លឺ (#1DD4FD) នៅផ្នែកខាងក្រោម។




## ជំហានទី 11

សម្រាប់រូបបន្ទាប់នេះគឺ Music app ដែលស្ថិតនៅលើតែធាតុប៉ុណ្ណោះជាសញ្ញាសម្គាល់តន្ត្រី។ ចាប់ផ្តើមជាមួយចតុកោណកែងប្រវែង 27 x 11 px ដោយធ្វើការជ្រើសរើសចំនុច anchor នៅលើផ្នែកខាងឆ្វេងនៃរូបជាមួយ Direct Selection Tool (A) ហើយទាញពួកគេទំលាក់ចុះក្រោមដើម្បីបង្កើតជារូបដូចខាងក្រោម។



## ជំហានទី 12

ប្រើ Rectangle Tool (M) ដើម្បីបង្កើតរូបពីរផ្សេងទៀត ហើយចាប់ផ្តើមពី “leg” នៃសញ្ញាសម្គាល់។





### ជំហានទី 13

ជ្រើសរើសចំណុច anchor ទាំងបីនៃរូបបួនជ្រុងដែលទាបជាងគេជាមួយ Direct Selection Tool (A) ហើយធ្វើការព័ទ្ធជុំវិញពួកវា។ បន្ទាប់មក Unite រូបទាំងនេះក្នុង Pathfinder ហើយបង្កើតជ្រុងរវាងរូបដែលព័ទ្ធដោយប្រើមុខងារ Live Corners។








### ជំហានទី 14

បន្ថែមផ្នែកទីពីរនៃសញ្ញា ហើយធ្វើវាឱ្យរូបទាំងមូលស្អាត និងមានរាងមូល។ បញ្ចប់វារូប icon ដោយដាក់ផ្ទៃខាងក្រោយ បំពេញវាដោយបន្ទាត់ទ្រេតពីពណ៌ទឹកក្រូច (#FA5D3B) ទៅពណ៌ផ្កាឈូក (#FF2968)។





### ជំហានទី 15

រូបចុងក្រោយនៃបណ្តុំ icon ដែលយើងធ្វើនេះជារូប Calendar icon វាងាយស្រួលជាងគេដោយគ្រាន់តែមានអក្សរស្ថិតនៅលើ បង្កើតវាជាមួយ Helvetica Neue font ហើយដាក់ពណ៌ផ្ទៃខាងក្រោយនៃរូបជាពណ៌ស ជាការស្រេច។






# Q&A

របៀបតាមដានកុំព្យូទ័រដំណើរការប្រព័ន្ធប្រតិបត្តិការ Windows 10 ឬ Tablet របស់អ្នកប្រសិនបើអ្នកបាត់។

របៀបប្រើប្រាស់កម្មវិធី Desktop Google Drive។

## សំណួរ

ឈ្មោះ: សៀវ សុខវេហា
sokveha@gmail.com

ជម្រាបសួរ! ខ្ញុំបាទឈ្មោះ សៀវ សុខវេហា ជាប្រិយមិត្តអ្នកអានរបស់ទស្សនាវដ្ដីទីក្រុងពត៌មានវិទ្យា និងទីក្រុងទូរស័ព្ទ ហើយរាល់ថ្ងៃខ្ញុំកំពុងសិក្សាផ្នែកព័ត៌មានបច្ចេកវិទ្យា (IT) នៅក្នុងសាកលវិទ្យាល័យវេស្ទើន (Western) ឆ្នាំទីពីរ ក្រុងកំពង់ចាម។ នៅពេលនេះប្អូនមានចម្ងល់មួយចំនួនចង់សួរខាងបងឱ្យជួយបកស្រាយ។ សំណួរទី១៖ សូមបងប្រាប់ពីរបៀបតាមដានកុំព្យូទ័រដំណើរការប្រព័ន្ធប្រតិបត្តិការ Windows 10 ឬ Tablet របស់អ្នកប្រសិនបើអ្នកបាត់? សំណួរទី ២៖ សូមបងជួយពន្យល់ពីរបៀបប្រើប្រាស់កម្មវិធី Desktop Google Drive។ សូមបងជួយបង្ហាញដល់ប្អូនដោយអនុគ្រោះ និងសូមអរគុណចំពោះការចែករំលែកនេះ។

## ចម្លើយ

សួស្ដី ប្អូន សៀវ សុខវេហា! ជាបឋមទស្សនាវដ្ដីទីក្រុងពត៌មានវិទ្យា និងទីក្រុងទូរស័ព្ទ សូមអរគុណដល់ប្អូនក៏ដូចជាប្រិយមិត្តអ្នកអានផ្សេងទៀតដែលតែងតែគាំទ្រទស្សនាវដ្ដីរបស់យើងកន្លងទៅនេះ ហើយក៏សូមអរគុណជាខ្លាំងចំពោះសំណួរប្អូនដែលបានសួរមកខាងបងដែលសំណួរនេះគឺពិតជាសំណួរដ៏ល្អ និងថ្មីៗក្ដៅៗថែមទៀត។ ដូច្នេះដើម្បីធ្វើការដោះស្រាយនូវបញ្ហាដែលប្អូនបានជួបប្រទះដូចនេះយើងខ្ញុំដែលជាក្រុមការងារក្នុងទស្សនាវដ្ដីទីក្រុងពត៌មានវិទ្យា និងទីក្រុងទូរស័ព្ទ សូមធ្វើការបង្ហាញប្រាប់លម្អិតនៅខាងក្រោមនេះអំពីសំណួរដែលប្អូនចង់ដឹង។

### របៀបតាមដានកុំព្យូទ័រដំណើរការប្រព័ន្ធប្រតិបត្តិការ Windows 10 ឬ Tablet របស់អ្នកប្រសិនបើអ្នកបាត់



**មានចម្ងល់សូមទំនាក់ទំនងមកកាន់យើងខ្ញុំ**

facebook: It City Magazine

ការ update ដ៏ធំបំផុតជាលើកដំបូងរបស់ប្រព័ន្ធប្រតិបត្តិការ Windows 10 កាលពីខែវិច្ឆិកា ឆ្នាំ ២០១៥ បានបន្ថែមលក្ខណៈពិសេសដោយបំពាក់នូវឧបករណ៍តាមដានមួយ។ ឥឡូវនេះអ្នកអាចបើកតាមដាន GPS និងកំណត់ទីតាំងពីចម្ងាយនៅពេលដែលអ្នកបាត់កុំព្យូទ័រ ឬក៏ tablet ដែលដំណើរការប្រព័ន្ធប្រតិបត្តិការ Windows 10 ដូចដែលអ្នកតាមដានលើ smartphone, tablet ឬ MacBook ជាដើម។

កាលពីមុន វាតម្រូវការកម្មវិធីទីបីដូចជាកម្មវិធី Prey។ ប៉ុន្តែឥឡូវនេះ វាត្រូវបានរួមបញ្ចូលសម្រាប់អ្នកប្រើប្រាស់គ្រប់គ្នាប្រើជាមួយនឹងគណនី Microsoft។ វាត្រូវបានបិទតាមលំនាំដើម ដូច្នេះអ្នកត្រូវតែបើកដំណើរការវាជាមុន មុនពេលដែលអ្នកបាត់ឧបករណ៍របស់អ្នក។

## ដែនកំណត់

មុនពេលដែលអ្នកបើកដំណើរការលក្ខណៈពិសេសនេះ អ្នកត្រូវដឹងថាវាមានដែនកំណត់មួយចំនួន។ វាគ្រាន់តែជាដំណោះស្រាយក្នុងការតាមដានឧបករណ៍ តែវាមិនអនុញ្ញាតឱ្យអ្នកលុប ឬចាក់សោកុំព្យូទ័ររបស់អ្នកពីចម្ងាយបាននោះទេ។ អ្នកក៏មិនអាចអោយឧបករណ៍របស់អ្នករោទ៍សំឡេង ឬថតរូបថតមនុស្សដែលប្រើឧបករណ៍របស់អ្នកជាមួយ webcam បាននោះដែរ។ វាគ្រាន់តែបង្ហាញអ្នកពីទីតាំងរបស់ឧបករណ៍អ្នកតែប៉ុណ្ណោះ! ក្រុមហ៊ុន Microsoft ប្រហែលជាអាចបន្ថែមលក្ខណៈពិសេសបន្ថែមលើសពីនេះទៀតនៅពេលអនាគត។

វាក៏មិនអាចធ្វើការតាមដានបានល្អដូចទូរសព្ទ័ដែរ។ អ្នកអាចដឹងអំពីទីតាំងរបស់ឧបករណ៍របស់អ្នកដោយស្វ័យប្រវត្តិបានលុះត្រាតែឧបករណ៍នោះបើកដំណើរការ និងតភ្ជាប់ទៅកាន់ប្រព័ន្ធអ៊ីនធឺណិត។

ចោរក៏អាចលុបប្រព័ន្ធប្រតិបត្តិការលើឧបករណ៍របស់អ្នក ហើយ restore វាក្នុង factory settings។ ដែលនេះនឹងបញ្ឈប់អ្នកពីការតាមដានឧបករណ៍នោះ។ ប្រព័ន្ធប្រតិបត្តិការ Windows 10 មិនបានផ្តល់នូវការការពារ factory reset protection នោះទេ។

## របៀបបើកដំណើរការ "Find My Device" ក្នុងប្រព័ន្ធប្រតិបត្តិការ Windows 10

ដើម្បីបើកដំណើរការកម្មវិធីតាមដាន ឧបករណ៍ សូមបើក Start menu ឬ Start screen ហើយជ្រើសយក Settings។

ប្រសិនបើអ្នកបាត់កុំព្យូទ័រឬក៏ tablet ដោយមិនទាន់បានកំណត់បើកដំណើរការកម្មវិធីតាមដាននោះមិនមានមធ្យោបាយណាអាចអោយអ្នកដំណើរការកម្មវិធីនេះពីចម្ងាយនោះទេ។




សូមទៅកាន់ Update & Security រួចយក Find My Device នៅក្នុង Settings app ដើម្បីស្វែងរកកម្មវិធីនេះ។ អ្នកនឹងតម្រូវឱ្យប្រើប្រាស់គណនី Microsoft ដើម្បីដំណើរការកម្មវិធីនេះ។ សូម log ចូលទៅកាន់គណនី Microsoft តាមរយៈកម្មវិធីរុករកដើម្បីតាមដានឧបករណ៍របស់អ្នកប្រសិនបើអ្នកបានបាត់។




អ្នកនឹងឃើញសារមួយដែលនិយាយថា "Find my device is off" ប្រសិនបើអ្នកមិនទាន់បានបើកដំណើរការវានៅឡើយ។ សូមចុចប៊ូតុង "Change" ដើម្បីដំណើរការ។ បើកដំណើរការជម្រើស "Save my device's location periodically" កុំព្យូទ័រដែលដំណើរការប្រព័ន្ធប្រតិបត្តិការ Windows 10 របស់អ្នកនឹងផ្ញើសារដោយស្វ័យប្រវត្តិនូវទីតាំងរបស់ខ្លួនទៅកាន់ Microsoft ដែលនេះនឹងអនុញ្ញាតឱ្យអ្នកដឹងពីទីតាំងឧបករណ៍របស់អ្នកទោះបីជាឧបករណ៍នោះមិនបានបើកដំណើរការឬភ្ជាប់ទៅកាន់អិនធើណេតក៏ដោយ អ្នកអាចមើលទីតាំងចុងក្រោយបាន។




ជ្រើសឈ្មោះសម្រាប់កុំព្យូទ័រអ្នកដើម្បីប្តូរឈ្មោះកុំព្យូទ័រ និងផ្តល់នូវឈ្មោះដែលអាចប្រើបានកាន់តែច្រើន សូមបើកដំណើរការ Settings app នៅលើកុំព្យូទ័រនិងជ្រើសយក System> About។ ចុចលើប៊ូតុង "Rename PC" រួចផ្តល់ឈ្មោះកុំព្យូទ័ររបស់អ្នកនូវឈ្មោះដ៏ល្អមួយ។




តាមដានឧបករណ៍របស់អ្នកដែលបានបាត់នៅពេលដែលអ្នកចង់តាមដានឧបករណ៍របស់អ្នកដែលបានបាត់ សូមបើកកម្មវិធីរុករករួចចូលទៅកាន់ account.microsoft.com/devices។ Sign in ជាមួយគណនី Microsoft ដែលអ្នកប្រើនៅលើឧបករណ៍របស់អ្នក។




អ្នកនឹងឃើញបញ្ជីឈ្មោះឧបករណ៍ដែលបានចុះក្នុងគណនី Microsoft របស់អ្នក។ សូមរំកិលរកបញ្ជីឈ្មោះឧបករណ៍ដែលអ្នកចង់តាមដាន។ អ្នកនឹងឃើញ "Last seen at [time] in [City]" នៅខាងស្តាំនៃឧបករណ៍នេះ។




សូមចុចលើតំណ "Find my device" ហើយអ្នកនឹងអាចតាមដានឧបករណ៍តាមរយៈផែនទី។ ប្រសិនបើឧបករណ៍នោះកំពុងតែដំណើរការ និងតភ្ជាប់ទៅអ៊ីនធឺណិតតាមរយៈ Wi-Fi ខ្សែ Ethernet ឬការភ្ជាប់ cellular ទីតាំងរបស់វានឹងបញ្ជាក់មកភ្លាមៗ។




ក្រុមហ៊ុន Microsoft បំពាក់ប្រព័ន្ធប្រតិបត្តិការ Windows 10 សម្រាប់ទូរស័ព្ទនិងកុំព្យូទ័រកាន់តែជិតគ្នា ។ កំណែ Desktop របស់ប្រព័ន្ធប្រតិបត្តិការ Windows 10 ឥឡូវនេះទទួលបាននូវលក្ខណៈពិសេសដែលពីមុនធ្លាប់មានតែនៅលើទូរស័ព្ទដែលប្រើប្រាស់ Windows។ កម្មវិធី "Find My Device" គ្រាន់តែជាឧទាហរណ៍មួយក្នុងចំណោមលក្ខណៈពិសេសទាំងអស់នេះ។ ប្រសិនបើអ្នកមានប្រព័ន្ធប្រតិបត្តិការ Windows 10 លើទូរស័ព្ទ អ្នកអាចបើកដំណើរការ "Find My Device" អ្នកក៏អាចដំណើរការកម្មវិធីនេះបានគ្រប់ពេលវេលាផងដែរ។

# របៀបប្រើប្រាស់កម្មវិធី Desktop Google Drive




កម្មវិធី Google Drive បានក្លាយជាជម្រើសផ្ទុកទិន្នន័យដ៏ល្អសម្រាប់អ្នកប្រើប្រាស់កុំព្យូទ័ររាប់លាននាក់ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយក៏សូមអរគុណចំពោះការដាក់ដំណើរការនៃការផ្តល់សេវា ដែលមានប្រជាប្រិយភាពបំផុតរបស់ក្រុមហ៊ុននេះ។ ប៉ុន្តែ តើអ្នកដឹងទេថា អ្នកក៏អាចទាញយកប្រយោជន៍ទាំងអស់ដែលមានក្នុងកម្មវិធីនេះតាមរយៈ Desktop របស់អ្នក?

នេះមានន័យថា អ្នកមិនចាំបាច់បើកដំណើរការកម្មវិធីរុករក ឬក៏រង់ចាំការតភ្ជាប់ទៅកាន់អ៊ីនធឺណិតដើម្បីទទួលបានទៅឯកសារដែលអ្នកត្រូវការនោះទេ។ ខាងក្រោមនេះជាការបង្ហាញអំពីរបៀបក្នុងការប្រើប្រាស់កម្មវិធី Google Drive នៅក្នុង Desktop។

ការទាញយកកម្មវិធីដើម្បីទាញយក Drive សម្រាប់ desktop របស់អ្នក អ្នកអាចធ្វើតាមរបៀបងាយៗ ២ យ៉ាង។ ជាដំបូងសូមអ្នកទៅកាន់ main drive profile របស់អ្នកនៅ "drive.google.com" និងចុចលើប៊ូតុង "Get Drive for PC" នៅជ្រុងខាងស្តាំនៃម៉ឺនុយ។




ទីពីរ គឺសូមទៅកាន់គេហទំព័រ (https://www.google.com/drive/download/) និងចុចលើប៊ូតុង "Get Drive for PC"។




អត្ថបទនៃប៊ូតុងនេះនឹងផ្លាស់ប្តូរអាស្រ័យទៅលើម៉ាស៊ីនដែលបណ្តាញរុករករបស់អ្នករកឃើញនៅពេលដែលអ្នកកំពុងធ្វើការ ប៉ុន្តែអ្នកក៏អាចជ្រើសលើការទាញយកដោយចុចលើម៉ឺនុយ drop down ដែលមានដូចការគូសបញ្ជាក់ខាងលើ។

## ប្រើប្រាស់ Drive នៅលើ Desktop របស់អ្នក

នៅពេលដែល Drive app ត្រូវបានតំឡើងរួចរាល់ហើយនោះ អ្នកនឹងឃើញរូបតំណាងថ្មីមួយចំនួនអណ្តែតឡើងជុំវិញ taskbar, desktop និង File Windows Explorer របស់អ្នក។



រូបតំណាង desktop នឹងភ្ជាប់ទៅកាន់ folder ដែលមានផ្ទុកឯកសារទាំងអស់របស់អ្នក ខណៈពេលដែលរូបតំណាង taskbar នឹងបង្ហាញ hotlist នៃឯកសារឬសៀវភៅបញ្ជីទាំងអស់ដែលអ្នកបានបើកកាលពីមុន។







លុះត្រាតែអ្នកទាញយកកម្មវិធីនេះតាមរយៈ window ដោយឡែកដូចនេះឯកសារទាំងអស់ដែលពាក់ព័ន្ធទៅនឹង Google Drive folder នឹងត្រូវរក្សាទុកក្នុង local កុំព្យូទ័រដែលជាតំណភ្ជាប់ទៅកាន់ online version of Drive។




ឯកសារនឹងបង្ហាញជា listed as local ប៉ុន្តែនៅពេលដែលអ្នកចុចលើវា វានឹងបើកដំណើរចូលទៅក្នុងកម្មវិធីរុករកជាមួយនឹងជម្រើសក្នុង login ទៅកាន់គណនីរបស់អ្នក ឬក៏ប្រសិនបើអ្នកបាន logged in រួចហើយ វានឹងដំណើរការឯកសារនៅក្នុង Google Docs, Sheet ឬក៏ Slides។




ហើយក៏គួរតែយល់ដឹងថា ឯកសារទាំងនេះមិនបានរក្សាទុកពិតនោះទេ ប្រសិនបើអ្នកលុបឯកសារណាមួយនៅក្នុង file explorer វានឹងត្រូវលុបចេញពី Google's servers ដូចគ្នា។




## ការកំណត់រចនាសម្ព័ន្ធ

ដើម្បីកំណត់រចនាសម្ព័ន្ធនៅលើ desktop Drive app សូម right click លើរូបតំណាង Drive ដែលមានទីតាំងនៅក្នុង Quick Access bar ( Windows 10 users ) ឬលើរូបតំណាង desktop។

ទស្សនាវដ្ដី

# ទីក្រុងទូរស័ព្ទ

PHONE CITY MAGAZINE




## ចេញផ្សាយរៀងរាល់ថ្ងៃទី ០១ នៃខែនីមួយៗ

### ផ្ដល់ជូននូវៈ

| | | | |
|---|---|---|---|
| ម៉ូដែលទូរស័ព្ទថ្មីៗ និងរបៀបប្រើប្រាស់ទូរស័ព្ទ | តារាងតម្លៃទូរស័ព្ទ | អត្ថបទកម្សាន្ត យ៉ាងសម្បូរបែប | ងាយស្រួលទាញយក តាមរយៈ Smart Phone ឬ Website |

អតិថិជនមិត្តអ្នកអានទាំងអស់អាចទាញយកទស្សនាទីក្រុងទូរស័ព្ទបានដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.phonecity.com.kh ឬសម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការ Android អាចទាញយកកម្មវិធី Phonecity បានតាមរយៈ Playstore ។

# OnHub

## Router ប្រភេទថ្មីក្នុងការកម្សាន្ត



**ជួបជាមួយ OnHub**

**Router ប្រភេទថ្មីសម្រាប់វិធីសាស្ត្រប្រើ Wi-Fi ថ្មី**

OnHub ជា router មួយប្រភេទដែលមានរូបរាងប្លែកពីគេ ប្រហាក់ប្រហែលទៅឧបករណ៍បំពងសំលេងដែលមានរាងមូលហើយទ្រវែងបន្តិច។ OnHub គឺជា router ដែល បានបង្កើតដោយ Google ដែលបានបង្កើតឡើងសម្រាប់គ្រប់ Wi-Fi ទាំងអស់។




**OnHub ផ្តល់ឱ្យអ្នកនូវ Wi-Fi ដែលមានល្បឿនលឿនលំហូរនៃល្បឿនសម្រាប់គ្រប់គ្នា**

OnHub បង្កើតឱ្យមានស្ទើរទាំងអស់នៃសេវាកម្មអ៊ីនធើណិត ដោយប្រើប្រាស់ software ដែលឆ្លាតវៃដើម្បីធ្វើការស្វែងរកការតភ្ជាប់ទៅកាន់ Wi-Fi ដែលល្អបំផុត។

**Bandwidth ពេលដែលអ្នកត្រូវការ**

ផ្តល់អាទិភាពទៅឱ្យឧបករណ៍ដូចនេះវានឹងធ្វើឱ្យល្បឿនរបស់ Wi-Fi កើនឡើងខ្លាំងបំផុតសម្រាប់សកម្មភាពសំខាន់ៗ ។

**ការសាយភាយ Wi-Fi**

ការរចនាអង់តែនរបស់ OnHub ជារាងរង្វង់ដែលប្រកបដោយភាពច្នៃប្រឌិតខ្ពស់ បានធ្វើឱ្យ Wi-Fi មានការគ្របដណ្តប់ទៅលើទិសដៅជាច្រើននៅក្នុងគេហដ្ឋានរបស់អ្នក។

**អត្ថប្រយោជន៍ក្នុងការឆ្លើយតប**

ប្រសិនបើវាធ្លាប់មានបញ្ហាជាមួយ network របស់អ្នក នៅលើកម្មវិធីរបស់ Google នឹងប្រាប់អ្នកថាតើវាជាអ្វីហើយគួរដោះស្រាយបែបណា។

### ងាយស្រួលតម្លើង

